ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# យុទ្ធសាស្ត្រជាតិ
# ស្តីពី
# ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ
# ឆ្នាំ២០២៥ - ២០៣០

រៀបចំដោយ
ក្រុមប្រឹក្សាជាតិស្តីពីអាហារូបត្ថម្ភជាតិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# យុទ្ធសាស្ត្រជាតិ

# ស្តីពី

# ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ

# ឆ្នាំ២០២៥-២០៣០

រៀបចំដោយ: ក្រុមប្រឹក្សាជាតិស្តីពីអាហារូបត្ថម្ភជាតិ

# អារម្ភកថា

អាហារូបត្ថម្ភ គឺជាសសរស្តម្ភដ៏សំខាន់ក្នុងការចូលរួមចំណែកលើកកម្ពស់សុខភាពសាធារណៈ បង្កើនផលិតភាពជាតិ និងកំណើនសេដ្ឋកិច្ចជាតិ។ អាហារូបត្ថម្ភគ្រប់គ្រាន់ជាមូលដ្ឋានក្នុងការចូលរួមលើកកម្ពស់សុខភាព និងសុខមាលភាពរបស់ប្រជាពលរដ្ឋ ជាពិសេសការអភិវឌ្ឍមូលធនមនុស្ស។ ទោះបីជាប្រទេសកម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ និងការកាត់បន្ថយភាពក្រីក្រក្នុងប៉ុន្មានទសវត្សរ៍ថ្មីៗនេះ ការអភិវឌ្ឍមូលធនមនុស្ស លទ្ធភាពទទួលបានរបបអាហារ សុខភាពប្រសើរជាងមុន ការបញ្ចប់បញ្ហាអាហារូបត្ថម្ភលើគ្រប់ទម្រង់ នៅតែជារបៀបវារៈជាតិដែលមិនទាន់សម្រេចបាននៅឡើយ។ គួរឱ្យកត់សម្គាល់ ប្រទេសកម្ពុជារងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយបញ្ហាអាហារូបត្ថម្ភ (ខ្វះ និងលើសអាហារូបត្ថម្ភ) ដែលជាបញ្ហាសុខភាពសាធារណៈដ៏សំខាន់មួយ ពិសេសស្ត្រីមានផ្ទៃពោះ ស្ត្រីបំបៅដោះកូន និងកុមារ។ បញ្ហាកង្វះអាហារូបត្ថម្ភ (ក្រិសក្រិន ស្គមស្គាំង ខ្វះទម្ងន់ និងកង្វះមីក្រូសារជាតិ) បង្កើនហានិភ័យនៃជំងឺនិងមរណភាព ដែលប៉ះពាល់ដល់ការអភិវឌ្ឍមូលធនមនុស្សជាពិសេសការលូតលាស់រាងកាយ សតិបញ្ញា សុខភាព និងបណ្តាលឱ្យផលិតភាពការងារចុះខ្សោយ។ បញ្ហាកង្វះអាហារូបត្ថម្ភ ធ្វើឱ្យកម្ពុជាខាតបង់យ៉ាងតិច ២៦០លានដុល្លារអាម៉េរិក ឬជិត២ភាគរយ នៃផលិតផលក្នុងស្រុកសរុប។ ការលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ ជាពិសេសសម្រាប់ស្ត្រីនិងកុមារ មានសក្តានុពលនាំមកនូវអត្ថប្រយោជន៍សម្រាប់សុខភាពសាធារណៈ ការអប់រំ និងសេដ្ឋកិច្ចសម្រាប់រយៈពេលមធ្យមនិងវែង។

អាហារូបត្ថម្ភជាអាទិភាពសម្រាប់ប្រទេសកម្ពុជា ដើម្បីសម្រេចបាននូវគោលដៅប្រកបដោយមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ គឺជាកិច្ចអន្តរាគមន៍និងជាយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាព មានតម្លៃសមរម្យក្នុងការលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ និងសុខភាពសាធារណៈដល់ប្រជាជនទូទៅ ជាពិសេសក្រុមប្រជាជនងាយរងគ្រោះដែលស្ថិតក្រោមយន្តការជំនួយសង្គមនានា។

ដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតនិងស្វាហាប់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នឹងបន្តពង្រឹងនិងពង្រីកការអនុវត្តកម្មវិធីបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារនៅកម្ពុជាឱ្យបានទូលំទូលាយនិងប្រកបដោយប្រសិទ្ធភាព ដើម្បីផ្តល់ផលវិជ្ជមាន លើការលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ សុខភាពសាធារណៈ និងការពង្រឹងប្រព័ន្ធគាំពារសង្គមនៅក្នុងប្រទេសកម្ពុជា។ ការពង្រឹងការអនុវត្តកម្មវិធីចំណីអាហារដែលបញ្ចូលមីក្រូសារជាតិទាមទារឱ្យមានតម្រូវការទីផ្សារ ការចូលរួមពីវិស័យឯកជន មានស្តង់ដាជាតិត្រឹមត្រូវ ធានាបាននូវការត្រួតពិនិត្យគុណភាព និងទំនុកចិត្តពីអ្នកប្រើប្រាស់។

ក្នុងសារលិខិតថ្លែងក្នុងទិវាជាតិអាហារូបត្ថម្ភ លើកទី១២ (៦ វិច្ឆិកា ២០២៥) ក្រោមប្រធានបទ "**អាហារូបត្ថម្ភដើម្បីសន្តិភាព សន្តិភាពដើម្បីអាហារូបត្ថម្ភ**" រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាជាតិស្តីពីអាហារូបត្ថម្ភជាតិក្រោមការដឹកនាំរបស់ក្រសួងផែនការ ត្រូវសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងវិស័យឯកជន បន្តពង្រឹងការអនុវត្តការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារឱ្យបានទូលំទូលាយនិងជំរុញការអនុម័តយុទ្ធសាស្ត្រជាតិ ស្តីពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារឆ្នាំ២០២៥-២០៣០។

# មាតិកា


**អារម្ភកថា**

**បញ្ជីពាក្យកាត់**

**សេចក្តីសង្ខេប**.......................................................................................................១

**១- សេចក្តីផ្តើម**........................................................................................................៣

**២- បរិបទប្រទេសនិងសនិទានភាព**..............................................................................៤

**៣- យុទ្ធសាស្ត្រជាតិ ស្តីពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ**.....................................៦

៣.១- មូលដ្ឋានទស្សនាទាន .....................................................................................៦

៣.២- ចក្ខុវិស័យ ......................................................................................................៧

៣.៣- គោលដៅ ........................................................................................................៧

៣.៤- សសរស្តម្ភគោលបំណងយុទ្ធសាស្ត្រ.......................................................................៧

៣.៥- ផ្នែកអាទិភាព...................................................................................................១០

៣.៥.១- ផ្នែកអាទិភាពនៃសកម្មភាព ..........................................................................១០

៣.៥.២- មធ្យោបាយក្នុងការពង្រីកវិសាលភាព..............................................................១១

៣.៦- សេចក្តីបរិយាយអំពីធាតុចេញយុទ្ធសាស្ត្រនិងសកម្មភាពស្នូល.........................................១២

៣.៦.១- **គោលបំណងយុទ្ធសាស្ត្រទី១** : ពង្រឹងអភិបាលកិច្ច កិច្ចសហការ និងសមត្ថភាព របស់ក្រសួង ស្ថាប័នពាក់ព័ន្ធសម្រាប់ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ .........១២

៣.៦.២- **គោលបំណងយុទ្ធសាស្ត្រទី២** : ជំរុញការប្រើប្រាស់អាហារដែលបញ្ចូល មីក្រូសារជាតិក្នុងយន្តការស្ថាប័ន និង កម្មវិធីគាំពារសង្គមដើម្បីលើកកម្ពស់ អាហារូបត្ថម្ភក្នុងចំណោមប្រជាជនគោលដៅ..................................................... ១៣

៣.៦.៣- **គោលបំណងយុទ្ធសាស្ត្រទី៣** : បង្កើនការផលិតអាហារដែលមានសុវត្ថិភាព និង អាហារដែលបញ្ចូលមីក្រូសារជាតិឱ្យបានគ្រប់គ្រាន់ ទៅតាមតម្រូវការរួមទាំងអំបិល ទឹកត្រី ទឹកស៊ីអ៊ីវ អង្ករ និងផលិតផលផ្សេងទៀត .............................................. ១៤

៣.៦.៤- **គោលបំណងយុទ្ធសាស្ត្រទី៤** : បង្កើតបរិយាកាសអំណោយផល និង រចនាសម្ព័ន្ធ លើកទឹកចិត្តធុរកិច្ច ក្នុងការវិនិយោគលើវិស័យអាហារដែលបញ្ចូលមីក្រូសារជាតិ.......១៦

៣.៦.៥- **គោលបំណងយុទ្ធសាស្ត្រទី៥** : ពង្រឹងបទប្បញ្ញត្តិនិងក្របខ័ណ្ឌគតិយុត្តលើ អាហារដែលបញ្ចូលមីក្រូសារជាតិនៅកម្រិតឧស្សាហកម្ម និង ទីផ្សារដើម្បីធានា គុណភាព សុវត្ថិភាព និង ការពារសិទ្ធិអ្នកបរិភោគជាសាធារណៈ.......................... ១៧

៣.៦.៦- **គោលចំណងយុទ្ធសាស្ត្រទី៦** : បង្កើនការយល់ដឹង និង ជំរុញតម្រូវការអ្នកប្រើប្រាស់សម្រាប់អាហារដែលបញ្ចូលមីក្រូសារជាតិ ....................២០

៣.៦.៧- **គោលចំណងយុទ្ធសាស្ត្រទី៧** : ការធានាការផ្តល់ហិរញ្ញប្បទានសម្រាប់ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ ....................២១

៤- **ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃសម្រាប់គណនេយ្យភាពនិងការសិក្សា**....................២៣

៤.១- ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ....................២៣

៤.២- ការបង្កើតភស្តុតាងនិងការសិក្សា....................២៤

៥- **ឧបសម្ព័ន្ធ**....................២៥

**គោលចំណងយុទ្ធសាស្ត្រទី១** : ពង្រឹងអភិបាលកិច្ច កិច្ចសហការ និង សមត្ថភាពរបស់ក្រសួងស្ថាប័នពាក់ព័ន្ធសម្រាប់កម្មវិធីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ....................២៥

**គោលចំណងយុទ្ធសាស្ត្រទី២** : ជំរុញការប្រើប្រាស់អាហារបញ្ចូលមីក្រូសារជាតិក្នុងយន្តការស្ថាប័ន និងកម្មវិធីគាំពារសង្គម ដើម្បីលើកកម្ពស់អាហារូបត្ថម្ភក្នុងចំណោមប្រជាជនគោលដៅ ....................២៦

**គោលចំណងយុទ្ធសាស្ត្រទី៣** : បង្កើនការផលិតអាហារដែលសុវត្ថិភាព និង អាហារដែលបញ្ចូលមីក្រូសារជាតិឱ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការរួមទាំង អំបិល ទឹកត្រី ទឹកស៊ីអ៊ីវ អង្ករ និងផលិតផលផ្សេងទៀត ....................២៧

**គោលចំណងយុទ្ធសាស្ត្រទី៤** : បង្កើតបរិយាកាសអំណោយផល និង រចនាសម្ព័ន្ធលើកទឹកចិត្តធុរកិច្ច ក្នុងការវិនិយោគលើវិស័យអាហារដែលបញ្ចូលមីក្រូសារជាតិ .................... ៣០

**គោលចំណងយុទ្ធសាស្ត្រទី៥** : ពង្រឹងបទប្បញ្ញត្តិ និង ក្របខ័ណ្ឌគតិយុត្ត លើអាហារដែលបញ្ចូលមីក្រូសារជាតិនៅកម្រិតឧស្សាហកម្មនិងទីផ្សារ ដើម្បីធានាគុណភាព សុវត្ថិភាព និងការពារសិទ្ធិអ្នកបរិភោគជាសាធារណៈ ....................៣២

**គោលចំណងយុទ្ធសាស្ត្រទី៦** : បង្កើនការយល់ដឹង និង ជំរុញតម្រូវការអ្នកប្រើប្រាស់សម្រាប់អាហារដែលបញ្ចូលមីក្រូសារជាតិ .................... ៣៨

**គោលចំណងយុទ្ធសាស្ត្រទី៧** : ការធានាការផ្តល់ហិរញ្ញប្បទានសម្រាប់ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ .................... ៣៩

ដូច្នេះគំនិតផ្តួចផ្តើមក្នុងការរៀបចំ **យុទ្ធសាស្ត្រជាតិ ស្តីពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ ឆ្នាំ២០២៥-២០៣០** គឺជាសេចក្តីត្រូវការចាំបាច់បន្ទាន់ និងជាមគ្គុទេសក៍ក្នុងការកំណត់តួនាទីភារកិច្ច និងការទទួលខុសត្រូវនៃការខិតខំប្រឹងប្រែង ដើម្បីធ្វើឱ្យស្ថានភាពអាហារូបត្ថម្ភរបស់ប្រជាជនកម្ពុជាកាន់តែប្រសើរឡើងថែមទៀតនិងស្របទៅតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០១៦-២០៣០ និងផ្អែកលើយុទ្ធសាស្ត្រជាតិ ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភលើកទី៣ យុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹត្យកាបូន គោលដៅឆ្នាំ២០៥០ ផែនការជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជាដំណាក់កាលទី៣ (NDC 3.0) និងគោលនយោបាយជាតិប្រជាជន ២០១៦-២០៣០។

ការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រជាតិ និងគោលការណ៍ណែនាំនានា នៅមានចំណុចខ្វះខាតដែលជាឧបសគ្គចម្បងសម្រាប់ការវិនិយោគរបស់វិស័យឯកជន ជាពិសេសក្នុងការពង្រឹងគុណភាពសុវត្ថិភាព និងអនុលោមភាពតាមស្តង់ដាជាតិដែលបានកំណត់ដោយរាជរដ្ឋាភិបាល ចំពោះផលិតផលម្ហូបអាហារទាំងអស់ក្នុងប្រទេស។ ភស្តុតាងនានាបានបង្ហាញថា អនុលោមភាពនិងសុក្រឹត្យភាពក្នុងការអនុវត្តស្តង់ដានិងក្របខ័ណ្ឌគតិយុត្តដែលបានកំណត់ដោយរាជរដ្ឋាភិបាល គឺមានភាពចាំបាច់សម្រាប់លើកទឹកចិត្តនិងបង្កើនទំនុកចិត្តពីវិស័យឯកជន ក្នុងការវិនិយោគលើការផលិតនិងធានាបាននូវកម្រិតសុវត្ថិភាព និងគុណភាពម្ហូបអាហារ។

រាជរដ្ឋាភិបាលកម្ពុជា បានបង្ហាញការប្តេជ្ញាចិត្តដើម្បីដោះស្រាយបញ្ហាកង្វះអាហារូបត្ថម្ភតាមរយៈការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ ដើម្បីដាក់ឱ្យអនុវត្តគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈ លិខិតបទដ្ឋានគតិយុត្តនិងប្រើប្រាស់យន្តការដែលមានស្រាប់ដូចជា ក្រុមប្រឹក្សាជាតិស្តីពីអាហារូបត្ថម្ភជាតិក្រោមការដឹកនាំរបស់ក្រសួងផែនការ។

ក្នុងនាមក្រុមប្រឹក្សាជាតិស្តីពីអាហារូបត្ថម្ភជាតិ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រសួង ស្ថាប័ន និងគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ដែលបានចូលរួមសហការ ឧបត្ថម្ភគាំទ្រ និងផ្តល់ធាតុចូលដល់ការរៀបចំយុទ្ធសាស្ត្រជាតិ ស្តីពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារនេះរហូតទទួលបានជោគជ័យ។ ខ្ញុំសូមអំពាវនាវដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល អ្នកស្រាវជ្រាវ និងវិស័យឯកជន ចូលរួមអនុវត្ត **យុទ្ធសាស្ត្រជាតិ ស្តីពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារឆ្នាំ២០២៥-២០៣០** នេះឱ្យទទួលបាននូវលទ្ធផលផ្លែផ្កាជាវិជ្ជមាន។

ថ្ងៃច័ន្ទ ១០រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ ធ្នូ ឆ្នាំ២០២៥

**រដ្ឋមន្ត្រីក្រសួងផែនការ និងជា**

**ប្រធានក្រុមប្រឹក្សាជាតិស្តីពីអាហារូបត្ថម្ភជាតិ**

(ត្រា៖ ក្រសួងផែនការ)

**ប៊ិន ត្រឈៃ**

## បញ្ជីពាក្យកាត់

| | | |
|---|---|---|
| អាស៊ាន | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ | Association of Southeast Asian Nations |
| ក.ក.ជ. | ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ | Council for Agricultural and Rural Development |
| ក.ប.ប. | អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ | Customer Protection, Competition and Fraud Repression |
| ស.ផ.ច.ក. | សមាគមអ្នកផលិតចំណីអាហារកម្ពុជា | Cambodia Food Manufacturer Association |
| ស.អ.ក. | សហព័ន្ធស្រូវអង្ករកម្ពុជា | Cambodia Rice Federation |
| ARDB | ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម | Agricultural and Rural Development Bank |
| CS | ស្តង់ដាកម្ពុជា | Cambodian Standard |
| CSES | របាយការណ៍អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា | Cambodia Socio-Economic Survey |
| DALY | អាយុសង្ឃឹមរស់របស់ជនមានពិការភាព | Disability-Adjusted Life Year |
| DP | ដៃគូអភិវឌ្ឍ | Development Partner |
| FAO | អង្គការស្បៀងនិងកសិកម្ម | Food and Agriculture Organization |
| FASMEC | សម្ព័ន្ធសមាគមសហគ្រាសធុនតូចនិងមធ្យមកម្ពុជា | Federation of Associations for SMEs of Cambodia |
| FORISCA | អង្ករដែលបញ្ចូលមីក្រូសារជាតិសម្រាប់កុមារក្នុងសាលារៀនកម្ពុជា | Fortified Rice for School Children in Cambodia |
| FRK | គ្រាប់អង្ករដែលបញ្ចូលមីក្រូសារជាតិ | Fortified Rice Kernel |
| GAIN | អង្គការសម្ព័ន្ធសកលសម្រាប់ការពង្រឹងអាហារូបត្ថម្ភ | Global Alliance for Improved Nutrition |
| ផ.ស.ស | ផលិតផលក្នុងស្រុកសរុប | Gross Domestic Product |
| GFT | សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរ | Garment, Footwear, and Travel goods |
| Helen Keller Intl | អង្គការហេឡែន ខេលល័រ អន្តរជាតិ | Helen Keller Intl |
| ILSI | វិទ្យាស្ថានវិទ្យាសាស្ត្រជីវិតអន្តរជាតិ | International Life Science Institute |
| IMTC | គណៈកម្មការបច្ចេកទេសអន្តរក្រសួង | Inter-Ministerial Technical Committee |
| ISC | វិទ្យាស្ថានស្តង់ដារកម្ពុជា | Institute of Standard of Cambodia |
| ISO | អង្គការស្តង់ដាអន្តរជាតិ | International Organization for Standardization |
| KI | ប៉ូតាស្យូមអ៊ីយ៉ូដ | Potassium Iodide |
| KIO | ប៉ូតាស្យូមអ៊ីយ៉ូដាត | Potassium Iodate |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | Ministry of Agriculture, Forestry and Fisheries |

| | | |
|---|---|---|
| MISTI | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | Ministry of Industry, Science, Technology and Innovation |
| MNP | ម្សៅមីក្រូសារជាតិ | Micronutrient Powder |
| MoC | ក្រសួងពាណិជ្ជកម្ម | Ministry of Commerce |
| MoH | ក្រសួងសុខាភិបាល | Ministry of Health |
| MoP | ក្រសួងផែនការ | Ministry of Planning |
| MoSVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | Ministry of Social Affairs, Veteran and Youth Rehabilitation |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា | Ministry of Education, Youth and Sports |
| MT | តោន | Metric Ton |
| NCDs | ជំងឺមិនឆ្លង | Non-Communicable Diseases |
| ក.ជ.អ.ជ. | ក្រុមប្រឹក្សាជាតិស្តីពីអាហារូបត្ថម្ភជាតិ | National Council for Nutrition |
| ម.ជ.វ.ប.ន | មន្ទីរពិសោធន៍ជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | National Laboratory of Science, Technology and Innovation |
| ម.ជ.ជ | មូលនិធិជាតិជំនួយសង្គម | National Social Assistance Fund |
| យ.ជ.ប.អ. | យុទ្ធសាស្ត្រជាតិ ស្តីពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ | National Strategy for Food Fortification |
| NSCFF | អនុគណៈកម្មការជាតិបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារនៅកម្ពុជា | National Sub-Committee for Food Fortification |
| NSCIDD | អនុគណៈកម្មការជាតិលុបបំបាត់បញ្ហាកង្វះជាតិអ៊ីយ៉ូដនៅកម្ពុជា | National Sub-Committee for Iodine Deficiency Disorder |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ | National Strategic Development Plan |
| NSPC | ក្រុមប្រឹក្សាជាតិគាំពារសង្គម | National Social Protection Committee |
| NSFF | យុទ្ធសាស្ត្រជាតិ ស្តីពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ | National Strategy for Food Fortification |
| PNCC | គណៈកម្មាធិការសម្របសម្រួលការងារអាហារូបត្ថម្ភ រាជធានី ខេត្ត | Provincial Nutrition Coordination Committee |
| QA | ការធានាគុណភាព | Quality Assurance |
| QC | ការត្រួតពិនិត្យគុណភាព | Quality Control |
| RACHA | សម្ព័ន្ធសុខភាពកុមារនិងសុខភាពបន្តពូជ | Reproductive and Child Health Alliance |
| RGC | រាជរដ្ឋាភិបាលកម្ពុជា | Royal Government of Cambodia |
| SBN | បណ្តាញធុរកិច្ចនៃចលនាបង្កើនអាហារូបត្ថម្ភកម្ពុជា | Scaling Up Nutrition Business Network |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | - ចំនួនអ្នកផលិតអាហារដែលបញ្ចូលមីក្រូសារជាតិដែលបានបណ្តុះបណ្តាល | 0 | ១៥ | | NCN, DP | |
| ១ | ផ្តល់ការពង្រឹងសមត្ថភាពជាក់ស្តែងដល់អ្នកផលិតសិប្បកម្ម/រោងម៉ាស៊ីន ដើម្បីបញ្ចូលមីក្រូសារជាតិក្នុងអាហារឱ្យស្របតាមបរិមាណដែលទីផ្សារត្រូវការរួមទាំងសមាសធាតុចាំបាច់សម្រាប់មុខទំនិញនីមួយៗ | | | | | MoC, MISTI | ២០២៥-២០៣០ |
| ១.១ | អង្ករដែលបញ្ចូលមីក្រូសារជាតិ : ដំណើរការនាំចូលគ្រាប់វីតាមីនដែលបញ្ចូលមីក្រូសារជាតិ និងនីតិវិធីនៃការបញ្ចេញទំនិញពីគយនិងរដ្ឋាករ ឧបករណ៍និងបរិក្ខារ គោលការណ៍ណែនាំផលិតកម្ម គោលការណ៍ណែនាំអំពីការធានានិងគ្រប់គ្រងគុណភាព (QA&QC) ផ្ទៃក្នុង | - ចំនួនឯកសារណែនាំដែលបានបង្កើតឡើង | 0 | ៣ | គោលការណ៍ណែនាំ | NCN, DP | |
| | | - ចំនួនអ្នកផលិតដែលបានបណ្តុះបណ្តាល | 0 | ៥ | របាយការណ៍ប្រចាំឆ្នាំ | NCN, DP | ២០២៥-២០៣០ |
| ១.២ | អំបិលអ៊ីយ៉ូដ : ដំណើរការនាំចូលម្សៅអ៊ីយ៉ូដ (Premix) និងនីតិវិធីនៃការបញ្ចេញទំនិញពីគយនិងរដ្ឋាករ សម្រាប់ប៉ូតាស្យូមអ៊ីយ៉ូដាយ (KI) ឬប៉ូតាស្យូមអ៊ីយ៉ូដាត ($KIO_3$) ឧបករណ៍បរិក្ខារ គោលការណ៍ណែនាំក្នុងការផលិត និងគោលការណ៍ណែនាំអំពីការធានានិងគ្រប់គ្រងគុណភាព (QA &QC) ផ្ទៃក្នុង | - ចំនួនឯកសារណែនាំដែលបានបង្កើតឡើង<br>- ចំនួនអ្នកផលិតដែលបានបណ្តុះបណ្តាល | 0<br>0 | ៣<br>១០ | គោលការណ៍ណែនាំ<br>របាយការណ៍ប្រចាំឆ្នាំ | NCN, DP | ២០២៥-២០៣០ |
| ១.៣ | ទឹកត្រី និងទឹកស៊ីអ៊ីវមានជាតិដែក : ដំណើរការនាំចូលសារធាតុផ្សំម្សៅជាតិដែក (premix) និងនីតិវិធីនៃការបញ្ចេញទំនិញពីគយនិងរដ្ឋាករ (សូដ្យូមអាយ៉ែនអ៊ីឌីធីអេ (NaFeEDTA) ឬអាយ៉ែនស៊ុលហ្វាត និងសាយត្រេត ($FeSO_4$+Citrate) ឧបករណ៍បរិក្ខារ គោលការណ៍ណែនាំ | - ចំនួនឯកសារណែនាំដែលបានបង្កើតឡើង<br>- ចំនួនអ្នកផលិតដែលបានបណ្តុះបណ្តាល | 0<br>0 | 0<br>0 | គោលការណ៍ណែនាំ<br>របាយការណ៍ប្រចាំឆ្នាំ | NCN, DP | ២០២៥-២០៣០ |




**រូបភាព ៣.១** : ក្របខ័ណ្ឌទស្សនាទានសម្រាប់ប្រព័ន្ធស្បៀង[7]

## ៣.២- ចក្ខុវិស័យ

ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ គឺជាចំណុចអាទិភាពជាតិមួយសំខាន់ដែលរួមចំណែកយ៉ាងសកម្មក្នុងការកាត់បន្ថយបញ្ហាកង្វះមីក្រូសារជាតិក្នុងប្រទេសកម្ពុជានៅឆ្នាំ២០៣០។

## ៣.៣- គោលដៅ

អាហារដែលបញ្ចូលមីក្រូសារជាតិ នឹងត្រូវបានផលិត ងាយស្រួលរកបាន និងអាចទទួលទានបានជាប្រចាំ។

## ៣.៤- សសរស្តម្ភគោលបំណងយុទ្ធសាស្ត្រ

ក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិ ស្តីពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ (រូបភាព ៣.២) ឆ្លុះបញ្ចាំងអំពីវិធីសាស្ត្រគ្រប់ជ្រុងជ្រោយនិងជាប្រព័ន្ធ ដើម្បីដោះស្រាយបញ្ហាកង្វះមីក្រូសារជាតិ។ ដោយឈរលើមូលដ្ឋានក្នុងក្របខ័ណ្ឌទស្សនាទាននៃប្រព័ន្ធស្បៀង ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះត្រូវបានបន្សុីជាមួយសមាសធាតុសំខាន់ៗនៃប្រព័ន្ធស្បៀង ដើម្បីធានានិរន្តរភាពនៃកម្មវិធីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ និង

---

[7] Marshall et al. 2021. Building a global food systems typology: A new tool for reducing complexity in food system analysis. Available at: Frontiers | Building a Global Food Systems Typology: A New Tool for Reducing Complexity in Food Sys...

វ៉ែខនិជដែលនាំឱ្យមានការកើនថ្លៃចំណាយ និងនាំឱ្យមិនមានការធ្វើតេស្តជាប្រចាំនោះទេ ដោយសារត្រូវការពេលវេលាច្រើន។ ដូច្នេះសមត្ថភាពរបស់មន្ទីរពិសោធន៍ក្នុងការវិភាគវីតាមីននិងសារជាតិវ៉ែខនិជនៅក្នុងអាហារដែលបញ្ចូលមីក្រូសារជាតិពិតជាមានសារៈសំខាន់ហើយត្រូវពង្រឹងបន្ថែម។

**សកម្មភាពស្នូលរួមមានៈ**

១- ធ្វើការវាយតម្លៃសមត្ថភាពរបស់មន្ទីរពិសោធន៍ ដូចជាការវិភាគសំណាកផ្ទុកវីតាមីន និងសារជាតិវ៉ែខនិជរបស់អាហារដែលបញ្ចូលមីក្រូសារជាតិ។ ការវាយតម្លៃនេះ ក៏មានរួមបញ្ចូលទាំងការពិនិត្យទៅលើឧបករណ៍ សម្ភារៈ បរិក្ខារ ជំនាញបុគ្គលិក ភស្តុភារ និងសមត្ថភាពប្រចាំឆ្នាំ។

២- ផ្តល់និងបំពាក់ឧបករណ៍ចាំបាច់ និងសម្ភារបរិក្ខារដល់មន្ទីរពិសោធន៍ដើម្បីធ្វើការវិភាគបែបបរិមាណលើសំណាកអាហារដែលបញ្ចូលមីក្រូសារជាតិ។

៣- បង្កើតគោលការណ៍ណែនាំសម្រាប់ការធ្វើតេស្តស្តង់ដាក្នុងមន្ទីរពិសោធន៍សម្រាប់ការវិភាគអាហារ ដែលបញ្ចូលមីក្រូសារជាតិ។

៤- ផ្តល់ការបណ្តុះបណ្តាលជំនាញដល់បុគ្គលិកមន្ទីរពិសោធន៍ក្នុងការវិភាគអាហារដែលបញ្ចូលមីក្រូសារជាតិ រួមទាំងវីតាមីននិងសារជាតិវ៉ែខនិជ។

៥- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដើម្បីធ្វើការទទួលស្គាល់គុណភាពមន្ទីរពិសោធន៍ និងធានាបាននូវការអនុលោមតាមស្តង់ដាអន្តរជាតិ (ISO)។

### ៣.៦.៦- គោលចំណងយុទ្ធសាស្ត្រទី៦ : បង្កើនការយល់ដឹង និង ជំរុញតម្រូវការអ្នកប្រើប្រាស់សម្រាប់អាហារដែលបញ្ចូលមីក្រូសារជាតិ

ការយល់ដឹង អំពីអត្ថប្រយោជន៍នៃអាហារដែលបញ្ចូលមីក្រូសារជាតិក្នុងចំណោមសាធារណជននៅមានកម្រិតដែលនេះជះឥទ្ធិពលអវិជ្ជមានដល់តម្រូវការអាហារដែលបញ្ចូលមីក្រូសារជាតិ។ ការលើកកម្ពស់ការយល់ដឹង ការធ្វើទីផ្សារ ការរចនា និងការអនុវត្តស្លាកសញ្ញា/ម៉ាកមានសារៈសំខាន់ដើម្បីជំរុញការផ្សព្វផ្សាយនិងបង្កើនតម្រូវការអាហារដែលបញ្ចូលមីក្រូសារជាតិ។

### ៣.៦.៦.១- លទ្ធផលសម្រេចបាន៦.១ : ការយល់ដឹងរបស់សាធារណជនអំពីអាហារដែលបញ្ចូលមីក្រូសារជាតិត្រូវបានលើកកម្ពស់

យុទ្ធនាការលើកកម្ពស់ការយល់ដឹង អំពីអត្ថប្រយោជន៍នៃអាហារដែលបញ្ចូលមីក្រូសារជាតិត្រូវតែបង្កើតឡើងនិងអនុវត្ត។ ការធ្វើអង្កេតអំពីចំណេះដឹង ឥរិយាបថ និងការអនុវត្ត (KAPs) ត្រូវធ្វើឡើងដើម្បីប្រមូលទិន្នន័យនិងផ្តល់ជាព័ត៌មានសម្រាប់បង្កើតយុទ្ធសាស្ត្រទីផ្សារសង្គម។

**សកម្មភាពស្នូលរួមមានៈ**

១- ធ្វើការអង្កេតទៅលើចំណេះដឹង ឥរិយាបថ និងការអនុវត្ត (KAPs) ដើម្បីប្រមូលទិន្នន័យនិងផ្តល់ជាព័ត៌មានសម្រាប់បង្កើតយុទ្ធសាស្ត្រទីផ្សារសង្គម។

២- បង្កើតស្លាកសញ្ញា/ម៉ាកយីហោសម្រាប់ផលិតផលអាហារនីមួយៗ ដែលបញ្ចូលមីក្រូសារជាតិដែលផលិតក្នុងស្រុកដើម្បីកសាងទំនុកចិត្ត និងការយល់ដឹងក្នុងចំណោមសាធារណជនដែលជាអ្នកប្រើប្រាស់ និងសម្រេចចិត្ត។

| | | |
|---|---|---|
| SDG | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព | Sustainable Development Goals |
| SME | សហគ្រាសធុនតូចនិងមធ្យម | Small and Medium Enterprises |
| SUN | ចលនាបង្កើនអាហារូបត្ថម្ភនៅកម្ពុជា | Scaling Up Nutrition |
| TWG-FSN | ក្រុមការងារបច្ចេកទេសស្ដីពីសន្តិសុខស្បៀង និង អាហារូបត្ថម្ភ | Technical Working Group for Food Security and Nutrition |
| UNICEF | អង្គការយូនីសេហ្វ | United Nations Children's Fund |
| USAID | ទីភ្នាក់ងារសហរដ្ឋអាម៉េរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ | United States Agency for International Development |
| WFP | កម្មវិធីស្បៀងអាហារពិភពលោក | World Food Programme |
| WHO | អង្គការសុខភាពពិភពលោក | World Health Organization |

## ៣.៦- សេចក្តីបរិយាយអំពីធាតុចេញយុទ្ធសាស្ត្រនិងសកម្មភាពស្នូល

គំនិតផ្តួចផ្តើមនៃការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារនៅកម្ពុជា មានបញ្ហាប្រឈមជាច្រើន ដែលក្នុងចំណោមកត្តាប្រឈមផ្សេងៗនោះ រួមមានការត្រួតពិនិត្យបទប្បញ្ញត្តិនៅមានកម្រិត ការមិនបន្សុីគ្នា នៃគុណភាព ថ្លៃដើមសារធាតុមីក្រូសារជាតិលាយស្រេច (Premix) ខ្ពស់ និងនីតិវិធីនាំចូលស្មុគស្មាញ សមត្ថភាពផលិតនិងការយល់ដឹងរបស់សាធារណជននៅមានកម្រិត កង្វះតម្រូវការ និងកង្វះទិន្នន័យអំពី បញ្ហាកង្វះមីក្រូសារជាតិ។

ការដោះស្រាយបញ្ហាប្រឈមទាំងនេះ តម្រូវឱ្យមានវិធីសាស្ត្រគ្រប់ជ្រុងជ្រោយនិងពហុវិស័យ ដើម្បីធានាបាននូវប្រសិទ្ធភាពនិងនិរន្តរភាពនៃគំនិតផ្តួចផ្តើមនៃការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ ក្នុងប្រទេសកម្ពុជា។ យុទ្ធសាស្ត្រនេះផ្តោតលើការពង្រឹងនិងពង្រីកកម្មវិធីការបញ្ចូលមីក្រូសារជាតិក្នុង ចំណីអាហារសំខាន់ៗចំនួនបី គឺការបញ្ចូលជាតិអ៊ីយ៉ូដក្នុងអំបិលជាសកល ការបញ្ចូលមីក្រូសារជាតិក្នុង អង្ករ និងការបញ្ចូលជាតិដែកក្នុងទឹកត្រីនិងទឹកស៊ីអ៊ីវ។ ទោះបីការបញ្ចូលជាតិដែកក្នុង ទឹកត្រី និង ទឹកស៊ីអ៊ីវ មិន មែនជាសកម្មភាពអាទិភាពនាពេលបច្ចុប្បន្ននេះក្តី ប៉ុន្តែស្តង់ដាទាំងនេះអាចនឹងត្រូវបានពិនិត្យឡើងវិញនា ពេលអនាគតដោយផ្អែកលើភស្តុតាងសុខភាពសាធារណៈនិងលទ្ធភាពចូលទីផ្សារ។ ការណែនាំអំពី ផលិតផលអាហារថ្មីៗដែលត្រូវបញ្ចូលមីក្រូសារជាតិរួមទាំងប្រេងឆា មី ម្សៅមី អាហារសម្រន់ និងបបរ ដែលបញ្ចូលមីក្រូសារជាតិអាចនឹងត្រូវបានពិចារណានាពេលអនាគត។

**តារាង ៣.២** : ទិដ្ឋភាពទូទៅនៃសារធាតុផ្សំមីក្រូសារជាតិក្នុងចំណីអាហារ

| ផលិតផលអាហារដែលបញ្ចូលមីក្រូសារជាតិ | សារធាតុមីក្រូសារជាតិលាយស្រេច (Premix) ដែលប្រើប្រាស់ជាទូទៅ |
|---|---|
| • អង្ករ | ជាតិដែក ស័ង្កសី វីតាមីនអា វីតាមីនបេ១ បេ៣ បេ៦ បេ៩ បេ១២ ** |
| • អំបិល | អ៊ីយ៉ូដ |
| • ទឹកត្រី ទឹកស៊ីអ៊ីវ | ជាតិដែក |

** B1 (Thiamin), B3 (Niacin), B6 (Pyridoxin), B9 (Folate), B12 (Cobalamin)

### ៣.៦.១- គោលបំណងយុទ្ធសាស្ត្រទី១ : ពង្រឹងអភិបាលកិច្ច កិច្ចសហការ និងសមត្ថភាពរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធសម្រាប់ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ

ការអនុវត្តកម្មវិធីបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ ស្ថិតនៅក្រោមយុត្តាធិការរបស់ក្រសួងជា ច្រើន ដែលជាកត្តានាំឱ្យមានភាពមិនច្បាស់លាស់ក្នុងការអនុវត្ត ការគ្រប់គ្រងត្រួតពិនិត្យ និងការសម្រប សម្រួលប្រកបដោយប្រសិទ្ធភាព។ តាមរយៈក្រុមប្រឹក្សាជាតិស្តីពីអាហារូបត្ថម្ភជាតិក្រោមការដឹកនាំរបស់ ក្រសួងផែនការ និងគណៈកម្មាធិការសម្របសម្រួលការងារអាហារូបត្ថម្ភរាជធានី ខេត្ត មានតួនាទីជាស្ថាប័ន សម្របសម្រួលដ៏សំខាន់។ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងពាណិជ្ជកម្ម សហការទទួលខុសត្រូវលើមុខងារត្រួតពិនិត្យជាផ្លូវការ។ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ អនុវត្តការត្រួតពិនិត្យផ្តោតលើផលិតកម្ម ចំណែកឯក្រសួងពាណិជ្ជកម្មអនុវត្តការត្រួតពិនិត្យផ្តោត លើការចែកចាយនិងការលក់រាយលើទីផ្សារ។ តួនាទីទំនួលខុសត្រូវនិងដែនយុត្តាធិការរបស់ក្រសួងជំនាញ

# សេចក្តីសង្ខេប

**យុទ្ធសាស្ត្រជាតិ ស្តីពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ ឆ្នាំ២០២៥-២០៣០** គឺជាផែនទីបង្ហាញផ្លូវកម្រិតថ្នាក់ជាតិក្នុងការដោះស្រាយបញ្ហាកង្វះមីក្រូសារជាតិ តាមរយៈការកំណត់គោលដៅនៃការបញ្ចូលមីក្រូសារជាតិក្នុងស្បៀងអាហារចម្បង។ យុទ្ធសាស្ត្រដែលត្រូវបានបង្កើតឡើង ស្របតាមអាទិភាពជាតិដូចជា យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភលើកទី៣ ឆ្នាំ២០២៤-២០២៨ និងផែនទីបង្ហាញផ្លូវស្តីពីប្រព័ន្ធស្បៀងកម្ពុជា ឆ្នាំ២០៣០នេះ មានគោលបំណងធ្វើឱ្យប្រសើរឡើងនូវលទ្ធផលសុខភាពនិងអាហារូបត្ថម្ភរបស់ប្រជាជន ជាពិសេសសម្រាប់ក្រុមប្រជាជនដែលងាយរងគ្រោះ (ស្ត្រីនិងកុមារ)។

បញ្ហាកង្វះមីក្រូសារជាតិរារាំងដល់ការអភិវឌ្ឍរាងកាយ បញ្ញា មុខងារប្រព័ន្ធភាពស៊ាំ និង ផលិតភាពការងារ។ យុទ្ធសាស្ត្រនេះ មានគោលដៅកាត់បន្ថយអត្រាប្រេវ៉ាឡង់នៃបញ្ហាកង្វះមីក្រូសារជាតិសំខាន់ៗ ជាពិសេសជាតិដែក អ៊ីយ៉ូដ ស័ង្កសី វីតាមីនអា និង អាស៊ីតហ្វូលីក ដែលមានសារៈសំខាន់ក្នុងការទទួលបានសុខភាពនិងអាហារូបត្ថម្ភគ្រប់គ្រាន់នៅគ្រប់ដំណាក់កាលនៃជីវិត។

ការបញ្ចូលមីក្រូសារជាតិ គឺជាដំណើរការបន្ថែមវីតាមីន និងសារធាតុរ៉ែខនិជសំខាន់ៗទៅក្នុងអាហារដែលត្រូវទទួលទានជាប្រចាំ ដែលរួមទាំងអង្ករ អំបិល ទឹកត្រី និងទឹកស៊ីអ៊ីវផងដែរ។ នេះគឺជាកិច្ចអន្តរាគមន៍ប្រព័ន្ធស្បៀង ដែលត្រូវបានទទួលស្គាល់ថាមានប្រសិទ្ធភាព ថ្លៃចំណាយទាប មានសុវត្ថិភាពនិងមានវិសាលភាពគ្របដណ្តប់បានទូលំទូលាយក្នុងការលុបបំបាត់និងទប់ស្កាត់បញ្ហាកង្វះមីក្រូសារជាតិដែលជាបញ្ហាសុខភាពសាធារណៈដ៏សំខាន់មួយ។ ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ គឺជាកត្តាជំរុញដ៏សំខាន់មួយសម្រាប់ការអភិវឌ្ឍមូលធនមនុស្ស និងមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍការយល់ដឹង ការបង្កើនផលិតភាពបុគ្គល ព្រមទាំងជំរុញឱ្យមានផលចំណេញផ្នែកសេដ្ឋកិច្ចសម្រាប់ប្រទេសជាតិផងដែរ។

យុទ្ធសាស្ត្រនេះ ក៏មានគោលបំណងសំខាន់ក្នុងការបញ្ជ្រាបព័ត៌មានអំពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារទៅក្នុងកម្មវិធីគាំពារសង្គម កម្មវិធីផ្តល់អាហារតាមសាលារៀន ការត្រៀមលក្ខណៈពេលមានអាសន្ន និងការធ្វើពាណិជ្ជកម្មនានា ព្រមទាំងជួយពង្រឹងបរិយាកាសគោលនយោបាយនិងបទប្បញ្ញត្តិ ដើម្បីគាំទ្រឱ្យមានផលប៉ះពាល់ជាវិជ្ជមានរយៈពេលវែងផងដែរ។

ដើម្បីសម្រេចគោលដៅដែលបានកំណត់ យុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើងដោយផ្អែកលើគោលបំណងចំនួនប្រាំពីរ៖

១- ពង្រឹងអភិបាលកិច្ច កិច្ចសហការ និងសមត្ថភាពរបស់ក្រសួងស្ថាប័នពាក់ព័ន្ធសម្រាប់ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ។

២- ជំរុញការប្រើប្រាស់អាហារដែលបញ្ចូលមីក្រូសារជាតិក្នុងយន្តការស្ថាប័ននិងកម្មវិធីគាំពារសង្គម ដើម្បីលើកកម្ពស់អាហារូបត្ថម្ភក្នុងចំណោមប្រជាជនគោលដៅ។

៣- បង្កើនការផលិតអាហារដែលមានសុវត្ថិភាពនិងអាហារដែលបញ្ចូលមីក្រូសារជាតិឱ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការ រួមទាំងអំបិល ទឹកត្រី ទឹកស៊ីអ៊ីវ និង អង្ករនិងផលិតផលផ្សេងទៀត។

៤- បង្កើតបរិយាកាសអំណោយផលនិងរចនាសម្ព័ន្ធលើកទឹកចិត្តធុរកិច្ចក្នុងការវិនិយោគលើវិស័យអាហារដែលបញ្ចូលមីក្រូសារជាតិ។

៥- ពង្រឹងបទប្បញ្ញត្តិនិងក្របខ័ណ្ឌគតិយុត្តលើអាហារដែលបញ្ចូលមីក្រូសារជាតិនៅកម្រិតឧស្សាហកម្មនិងទីផ្សារ ដើម្បីធានាគុណភាពសុវត្ថិភាព និងការពារសិទ្ធិអ្នកបរិភោគជាសាធារណៈ។

៦- បង្កើនការយល់ដឹងនិងជំរុញតម្រូវការអ្នកប្រើប្រាស់សម្រាប់អាហារដែលបញ្ចូលមីក្រូសារជាតិ។

៧- ផ្តល់ហិរញ្ញប្បទានសម្រាប់ការអនុវត្តការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ។

ការអនុវត្តយុទ្ធសាស្ត្រនេះ ត្រូវផ្តោតលើសកម្មភាពដែលបានកំណត់យ៉ាងលម្អិតនៅក្នុងសសរស្តម្ភនីមួយៗ។ សកម្មភាពអាទិភាពទាំងនោះរួមមាន ការបង្កើតក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ ការបង្កើនតម្រូវការរបស់ស្ថាប័ន ការពង្រឹងអនុលោមភាព ការបង្កើតតម្រូវការតាមរយៈការផ្លាស់ប្តូរឥរិយាបថសង្គម ការវិនិយោគលើប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ និងការផ្តល់ហិរញ្ញប្បទានសម្រាប់ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ។

យុទ្ធសាស្ត្រនេះបានរៀបរៀងឡើងឱ្យស្របនឹងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងដើម្បីចូលរួមចំណែកក្នុងការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការកសាងប្រព័ន្ធស្បៀងប្រកបដោយចីរភាពនិងមានភាពធន់ ពង្រឹងការអភិវឌ្ឍមូលធនមនុស្ស និងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅឆ្នាំ២០៣០។

## ១- សេចក្តីផ្តើម

នៅទូទាំងពិភពលោក បញ្ហាកង្វះជាតិអ៊ីយ៉ូដ ជាតិដែក វីតាមីនអា និងស័ង្កសី គឺជាកត្តាហានិភ័យសុខភាពនិងអាហារូបត្ថម្ភដ៏ធ្ងន់ធ្ងរបំផុត។[1] [2] [3] ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ គឺជាកិច្ចអន្តរាគមន៍នៃប្រព័ន្ធស្បៀងមួយដែលត្រូវបានបង្កើតឡើង ដោយមានកំណត់ត្រាបង្ហាញអំពីភាពជោគជ័យក្នុងការលុបបំបាត់បញ្ហាកង្វះវីតាមីននិងសារធាតុរ៉ែខនិជ ដែលគេស្គាល់ថាជា "ភាពអត់ឃ្លានលាក់មុខ" ដែលជាក្តីកង្វល់សុខភាពសាធារណៈដ៏សំខាន់មួយ។

ជាទូទៅការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ គឺជាដំណើរការបន្ថែមវីតាមីននិងសារជាតិរ៉ែខនិជសំខាន់ៗទៅក្នុងអាហារដែលទទួលទានទូទៅ (តារាង ១.១) ដើម្បីបង្កើនបរិមាណអាហារូបត្ថម្ភ។ យោងតាមសេចក្តីណែនាំរបស់អង្គការសុខភាពពិភពលោក (WHO) ការបញ្ចូលមីក្រូសារជាតិទៅក្នុងអាហារដែលរៀបចំនិងអនុវត្តត្រឹមត្រូវ គឺជាយុទ្ធសាស្ត្រមួយដែលមានភាពងាយស្រួល មានប្រសិទ្ធភាព និងមានវិសាលភាពគ្របដណ្តប់ទូលំទូលាយសម្រាប់ប្រជាជនទាំងអស់ ក្នុងការដោះស្រាយនិងទប់ស្កាត់បញ្ហាកង្វះមីក្រូសារជាតិ។ យោងតាមកិច្ចព្រមព្រៀងទីក្រុង Copenhagen គេបានប៉ាន់ប្រមាណថារាល់ការចំណាយប្រាក់១ដុល្លារអាម៉េរិក នឹងទទួលបានផលចំណេញសេដ្ឋកិច្ចចំនួន២៧ដុល្លារអាម៉េរិកមកវិញក្នុងរយៈពេលវែងតាមរយៈការកាត់បន្ថយការមានជំងឺ ជួយបង្កើនប្រាក់ចំណូល និងផលិតភាពការងារកាន់តែល្អប្រសើរ។[4] អង្ករនិងគ្រឿងផ្សំដូចជាអំបិល ទឹកត្រី និងទឹកស៊ីអ៊ីវ គឺជាអាហារបរិភោគចម្បងរបស់ប្រជាជនកម្ពុជា ដូច្នេះអាហារទាំងនោះត្រូវបានចាត់ទុកថាជាយានដ៏សំខាន់ក្នុងការបញ្ចូលមីក្រូសារជាតិចាំបាច់សម្រាប់ប្រជាជនទូទៅជាពិសេសស្ត្រីនិងកុមារ។

**តារាង១.១** : ផលិតផលអាហារទូទៅដែលអាចបញ្ចូលមីក្រូសារជាតិបាន[5]

| ផលិតផលអាហារ | សារធាតុរ៉ែខនិជនិងវីតាមីនលាយស្រេច (Premix) ដែលប្រើប្រាស់ជាទូទៅ |
|---|---|
| • អំបិល | អ៊ីយ៉ូដ ជាតិដែក |
| • ម្សៅ (ស្រូវសាលី ពោត) | ជាតិដែក អាស៊ីតហ្វូលីក វីតាមីនអា វីតាមីនបេ១២ បេ១ (thiamine) បេ៦ (riboflavin) បេ៩ (niacin) កាល់ស្យូម |
| • ទឹកត្រី ទឹកស៊ីអ៊ីវ | ជាតិដែក |
| • ប្រេងឆា | វីតាមីនអា វីតាមីនដេ |
| • ផលិតផលទឹកដោះ | ជាតិដែក វីតាមីនអា វីតាមីនដេ អ៊ីយ៉ូដ |
| • អង្ករ | ជាតិដែក អាស៊ីតហ្វូលីក វីតាមីនអា វីតាមីនបេ១២ បេ១ បេ២ បេ៣ បេ៩ និងស័ង្កសី |

រាជរដ្ឋាភិបាលកម្ពុជា បានអនុម័តឱ្យប្រើប្រាស់ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារជាវិធានការបង្ការតាំងពីឆ្នាំ១៩៩៦ តាមរយៈការបង្កើតអនុគណៈកម្មការជាតិលុបបំបាត់បញ្ហាកង្វះជាតិអ៊ីយ៉ូដនៅកម្ពុជា។ ក្នុងន័យនេះការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ គឺជាកិច្ចអន្តរាគមន៍ដ៏សំខាន់មួយក្នុងការប្រយុទ្ធប្រឆាំងនឹងបញ្ហាកង្វះមីក្រូសារជាតិ ដែលត្រូវបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

[1] The Lancet Series
[2] Santiago-Fernandez et al. 2004, Intelligence Quotient and Iodine Intake: A Cross Sectional Study in Child. Available at: https://pubmed.ncbi.nlm.nih.gov/15292317/
[3] van Mil N.H et al. Low Urinary Iodine Excretion during Early Pregnancy Is Associated with Alterations in Executive Functioning in Children1–3. Journal of Nutrition Epidemiology
[4] Expert Panel Findings. Copenhagen Consensus. Solving the word's challenges. Copenhagen, Denmark 2012.
[5] Source: WHO and FAO Guidelines 2006, WHO MNP Guidelines, 2016.

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | - ភាគរយនៃផលិតផលទឹកត្រី ទឹកស៊ីអ៊ីវមានជាតិដែកដែលអនុលោមតាមស្តង់ដាទីផ្សារ | | | | NCN, MISTI, MoC, DP | |
| | | - ភាគរយនៃផលិតផលអំបិលអ៊ីយ៉ូដដែលអនុលោមតាមស្តង់ដាទីផ្សារ<br>- ភាគរយនៃផលិតផលអង្ករដែលបញ្ចូលមីក្រូសារជាតិដែលអនុលោមតាមស្តង់ដាទីផ្សារ | | ១០០% សម្រាប់អំបិល<br>៥០% សម្រាប់អង្ករ | | NCN, MISTI, MoC, DP | |
| | | - ចំនួនប្រព័ន្ធរាយការណ៍ស្តង់ដាដែលបានបង្កើតឡើង | 0 | ១ | | NCN, MISTI, MoC, DP | |
| ១ | ពង្រឹងសមត្ថភាពនិងកែសម្រួលនីតិវិធីអធិការកិច្ចសម្រាប់អាហារដែលបញ្ចូលមីក្រូសារជាតិក្នុងកម្រិតផលិតកម្ម ការចែកចាយ និងក្នុងទីផ្សារ | - ចំនួននីតិវិធីអធិការកិច្ចដែលបានបង្កើតឡើង | 0 | ១ | របាយការណ៍ប្រចាំឆ្នាំ | NCN, DP | ២០២៥-២០២៦ |
| ២ | បង្កើតនិងអនុវត្តផែនការសកម្មភាពអធិការកិច្ចលើការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារថ្នាក់ជាតិ រួមមានប៉ារ៉ាម៉ែត្រច្បាស់លាស់ស្តីពី វំញឹកភាព ការយកសំណាកគំរូ ដែនគ្របដណ្តប់ ទីតាំងភូមិសាស្ត្រជាដើម សម្រាប់អាហារដែលបញ្ចូលមីក្រូសារជាតិនីមួយៗ ដើម្បីពង្រឹងអនុលោមភាពក្នុងវិស័យឧស្សាហកម្មនិងទីផ្សារ រួមទាំងវិធានការចំពោះការមិនអនុលោមតាមច្បាប់ | -ចំនួនផែនការអធិការកិច្ចការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារដែលបានបង្កើតឡើង | 0 | ១ | របាយការណ៍ប្រចាំឆ្នាំ | NCN, DP | ២០២៥-២០២៦ |
| ៣ | ពង្រឹងសមត្ថភាពរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងការត្រួតពិនិត្យទីតាំង | - ចំនួនមន្ត្រីអធិការកិច្ចក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលត្រូវបានបណ្តុះបណ្តាលលើនីតិវិធីអធិការកិច្ច | 0 | ១២៥ | របាយការណ៍ប្រចាំឆ្នាំ | NCN, MISTI | ២០២៧-២០៣០ |

(NSDP) យុទ្ធសាស្ត្រជាតិ ស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ (NSFSN) ផែនការជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា ដំណាក់កាលទី៣ (NDC 3.0) ផែនការយុទ្ធសាស្ត្រ៥ឆ្នាំរបស់ក្រសួងព័ត៌មាន ស្តីពីទំនាក់ទំនងផ្លាស់ប្តូរឥរិយាបថសម្រាប់ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ ឆ្នាំ២០២៦-២០៣០ និងឯកសារគោលនយោបាយពាក់ព័ន្ធដទៃទៀត។

រាជរដ្ឋាភិបាលកម្ពុជា មានគោលបំណងលើកកម្ពស់សុខភាពនិងផលិតភាពរបស់ប្រជាពលរដ្ឋតាមរយៈគំនិតផ្តួចផ្តើមនៃការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារនេះ ជាពិសេសផ្តោតលើក្រុមគោលដៅដែលងាយរងគ្រោះបំផុតអំពីបញ្ហាកង្វះមីក្រូសារជាតិ រួមមានស្ត្រី កុមារអាយុក្រោម៥ឆ្នាំ កុមារក្នុងវ័យសិក្សា មនុស្សវ័យជំទង់ កម្មករ កម្មការិនីរោងចក្រវាយនភណ្ឌនិងកាត់ដេរ មនុស្សចាស់ ជនមានពិការភាព និងជនជាតិដើមភាគតិច។

## ២- បរិបទប្រទេសនិងសនិទានភាព

ទោះបីជាមានការរីកចម្រើនផ្នែកសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ក៏ដោយ ក៏កម្ពុជានៅតែមានការប្រឈមនឹងបន្ទុកបញ្ហាអាហារូបត្ថម្ភចម្បងចំនួន៣ រួមមានកង្វះអាហារូបត្ថម្ភ កង្វះមីក្រូសារជាតិ និងការកើនឡើងនៃបញ្ហាលើសទម្ងន់និងជំងឺធាត់ ដែលជាវិបត្តិរបស់ជាតិដែលបណ្តាលមកពីការផ្លាស់ប្តូររបបអាហារនិងប្រព័ន្ធស្បៀងយ៉ាងឆាប់រហ័ស ដោយសារការផ្លាស់ប្តូរបរិស្ថានស្បៀងនិងឥរិយាបថបរិភោគអាហារដែលជះឥទ្ធិពលមិនល្អចំពោះសុខភាពក្នុងចំណោមប្រជាជនទូទៅ។ យោងតាមរបាយការណ៍ស្ថានភាពសន្តិសុខស្បៀងនិងអាហារូបត្ថម្ភសកលលោកឆ្នាំ២០២៥ (The State of Food Security and Nutrition in the World (SOFI) 2025) [6] បង្ហាញថាការកាត់បន្ថយអត្រាស្លេកស្លាំង ក្នុងចំណោមស្ត្រីក្នុងវ័យបន្តពូជអាយុចាប់ពី១៥ ទៅ៤៩ឆ្នាំ បានត្រឹមតែ៣៨ភាគរយ ត្រឹមឆ្នាំ២០២៣ បើប្រៀបធៀបនឹងឆ្នាំ២០១២ ដែលមានអត្រា៣៩,៥ភាគរយ។ សម្រាប់ស្ថានភាពអាហារូបត្ថម្ភកុមារមានលទ្ធផលប្រសើរក្នុងចន្លោះ ឆ្នាំ២០១២និង២០២៤ ដែលអត្រាក្រិសក្រិនក្នុងចំណោមកុមារដែលមានអាយុក្រោម៥ឆ្នាំ បានធ្លាក់ចុះពី៣៤ភាគរយ មកត្រឹម២២ភាគរយ។ ផ្ទុយទៅវិញ អត្រាស្គមស្គាំងកុមារអាយុក្រោម៥ឆ្នាំមិនមានការប្រែប្រួលឡើយ គឺនៅមានអត្រា៩,៦ភាគរយ (ដែលនេះមានន័យថាក្នុងចំណោមកុមារ១០នាក់មានម្នាក់ស្គមស្គាំង) ហើយត្រឹមឆ្នាំ២០២៤ ពួកគេនៅតែបន្តរងផលប៉ះពាល់សុខភាពនិងគំរាមកំហែងអាយុជីវិត។ អត្រាប្រេវ៉ាឡង់នៃកុមារលើសទម្ងន់អាយុក្រោម៥ឆ្នាំ ត្រូវបានប៉ាន់ប្រមាណ៥,៧ភាគរយ ក្នុងឆ្នាំ២០២៤ ច្រើនជាងពីរដងលើអត្រា (២,១ភាគរយ) ដែលប៉ាន់ប្រមាណក្នុងឆ្នាំ២០១២។ អត្រាបច្ចុប្បន្នក៏នៅតែខ្ពស់ជាងមធ្យមភាគក្នុងតំបន់អាស៊ីអាគ្នេយ៍ (៤,៣ភាគរយ) ផងដែរ។ និន្នាការនិងលទ្ធផលអាហារូបត្ថម្ភទាំងនេះ បង្ហាញយ៉ាងច្បាស់អំពីតម្រូវការបង្កើនកិច្ចអន្តរាគមន៍និងវិធានការបង្ការ ដើម្បីដោះស្រាយទាំងបញ្ហានិងហានិភ័យដែលកំពុងកើតមាន។

បញ្ហាប្រឈមនៃអាហារូបត្ថម្ភទាំងនេះ បញ្ជាក់អំពីសារៈសំខាន់នៃការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីចាត់អាទិភាពក្នុងការអនុវត្តការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារដែលជាវិធានការមានប្រសិទ្ធភាពក្នុងការដោះស្រាយលើបញ្ហាអាហារូបត្ថម្ភ។ ការអនុម័តនិងការអនុវត្ត**យុទ្ធសាស្ត្រជាតិ ស្តីពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ** ដើរតួនាទីយ៉ាងសំខាន់ក្នុងការដោះស្រាយបញ្ចប់បញ្ហាកង្វះ

[6] FAO, IFAD, UNICEF, WFP and WHO. 2025. The State of Food Security and Nutrition in the World 2025 – Addressing high foodprice inflation for food security and nutrition. Rome. https://doi.org/10.4060/cd6008en

មីក្រូសារជាតិ ដើម្បីធ្វើឱ្យប្រសើរឡើងនូវសុខភាពទូទៅ និងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនដែលងាយរងគ្រោះ រួមទាំងស្ត្រីនិងកុមារផងដែរ។

ជាក់ស្តែង យោងតាមការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាឆ្នាំ២០១៤ បង្ហាញថា ៦០ភាគរយនៃស្ត្រីក្នុងវ័យបន្តពូជ ជួបបញ្ហាកង្វះជាតិអ៊ីយ៉ូដ ស័ង្កសី ព្រមទាំងមីក្រូសារជាតិសំខាន់ៗផ្សេងទៀតរួមមានជាតិដែក អាស៊ីតហ្វូលីក វីតាមីន បេ១ និងវីតាមីនដេ។ លើសពីនេះ កុមារជាង៩៣ភាគរយ ដែលមានអាយុពី៦ដល់១៦ឆ្នាំ មានកង្វះជាតិស័ង្កសី ហើយប្រហែល៥០ភាគរយ មានបញ្ហាកង្វះជាតិដែក និងកុមារជាច្រើនផ្សេងទៀតមានបញ្ហាកង្វះអ៊ីយ៉ូដ អាស៊ីតហ្វូលីក (Perignon ឆ្នាំ២០១៦)។ ខណៈតួលេខទាំងនេះទទួលបានមកពីការអង្កេតនាពាក់កណ្តាលទសវត្សរ៍ឆ្នាំ២០១០ ក៏ដោយ យោងតាមការអង្កេតអំពីការបរិភោគអាហារបច្ចុប្បន្ននិងទិន្នន័យរបបអាហារក៏នៅតែបង្ហាញអំពីបញ្ហាកង្វះមីក្រូសារជាតិសំខាន់ៗទាំងនេះ ក្នុងចំណោមក្រុមប្រជាពលរដ្ឋងាយរងគ្រោះដដែល។

ទោះបីមានបញ្ហាកង្វះទិន្នន័យ តំណាងជាតិនាពេលថ្មីៗលើបញ្ហាកង្វះមីក្រូសារជាតិក៏ដោយក៏យុទ្ធសាស្ត្រនេះត្រូវបានដឹកនាំបង្កើតឡើង ដោយផ្អែកលើភស្តុតាងថ្មីៗផ្សេងទៀតដែលអាចស្រាវជ្រាវបាននិងគំរូនៃការអនុវត្តល្អបំផុតជាសកល។ ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារជាអន្តរាគមន៍សុខភាពសាធារណៈដែលមានគុណភាព សុវត្ថិភាព មានតម្លៃទាប និងត្រូវបានណែនាំដោយ WHO ដែលអាចត្រូវបានអនុវត្តក្នុងកម្រិតមួយ ដើម្បីការពារកង្វះមីក្រូសារជាតិនិងធ្វើឱ្យសុខភាពប្រជាជនមានភាពប្រសើរឡើង។

វីតាមីននិងសារធាតុរ៉ែខនិជ រួមមានជាតិដែក អ៊ីយ៉ូដ  និងវីតាមីនអា សុទ្ធសឹងជាសារធាតុចាំបាច់សម្រាប់សុខភាពនិងការរស់រានមានជីវិតនៅគ្រប់ដំណាក់កាល។ បញ្ហាកង្វះមីក្រូសារជាតិបានរារាំងដល់ការអភិវឌ្ឍការយល់ដឹង មុខងារប្រព័ន្ធភាពស៊ាំ និងផលិតភាពការងារ។ ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារទ្រង់ទ្រាយធំ គឺជាកត្តាជំរុញដ៏សំខាន់មួយសម្រាប់ការអភិវឌ្ឍមូលធនមនុស្សចាំបាច់សម្រាប់ការអភិវឌ្ឍការយល់ដឹង ការបង្កើនផលិតភាពបុគ្គល ព្រមទាំងជំរុញឱ្យមានផលចំណេញផ្នែកសេដ្ឋកិច្ចសម្រាប់ប្រទេសជាតិផងដែរ។

កិច្ចខំប្រឹងប្រែងនៃការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហាររបស់កម្ពុជា បានចាប់ផ្តើមឡើងក្នុងកម្មវិធីបញ្ចូលសារជាតិអ៊ីយ៉ូដក្នុងអំបិលជាសកល (Universal Salt Iodization) នៅឆ្នាំ១៩៩៦ និងបានដាក់ឱ្យអនុវត្តជាកាតព្វកិច្ចផ្លូវការនៅឆ្នាំ២០០៣ (អនក្រ.បក ៦៩)។ ការបញ្ចូលមីក្រូសារជាតិជាតិដែកក្នុងទឹកត្រីនិងទឹកស៊ីអ៊ីវ ដែលត្រូវបានដាក់អនុវត្តសាកល្បងនៅឆ្នាំ២០០៥ អនុវត្តតាមការស្ម័គ្រចិត្តឆ្នាំ២០១១ និងតម្រូវឱ្យអនុវត្តជាកាតព្វកិច្ចផ្លូវការនៅឆ្នាំ២០១៥ បញ្ហាប្រឈមជាច្រើនត្រូវបានជួបប្រទះដូចជា ថ្លៃដើមផលិតកម្មខ្ពស់ កង្វះវត្ថុធាតុដើម (ម្សៅជាតិដែក) ដែលមិនមានចរាចរនៅក្នុងស្រុកនិងតម្រូវការអ្នកប្រើប្រាស់មានកម្រិត។ នៅឆ្នាំ២០២៥  វិទ្យាស្ថានស្តង់ដារកម្ពុជា បានកែសម្រួលស្តង់ដាCS ០០៥:២០០៣ (Rev.២:២០២៤) និង CS ០៦៦:២០១១ (Rev.២:២០២៤) ដោយធ្វើឱ្យការដាក់បញ្ចូលសារជាតិដែកក្លាយទៅជាជម្រើសស្ម័គ្រចិត្តទៅវិញ។ ការផ្លាស់ប្តូរនេះ គឺបណ្តាលមកពីមិនមានភស្តុតាងច្បាស់លាស់ ដែលបង្ហាញថាបញ្ហាកង្វះជាតិដែកនៅតែជាក្តីកង្វល់សំខាន់ចំពោះសុខភាពសាធារណៈ ឧបសគ្គផ្នែកសេដ្ឋកិច្ច និងការប្រកួតប្រជែងជាមួយនឹងផលិតផលនាំចូល។ ផ្ទុយទៅវិញការបញ្ចូលមីក្រូសារជាតិក្នុងអង្ករ ដែលបានណែនាំដោយ WFP នៅឆ្នាំ២០១០ និងពង្រីកវិសាលភាពអនុវត្តនៅឆ្នាំ២០១៥ បានបង្ហាញអំពីសក្តានុពលខ្លាំង ហើយឥឡូវនេះត្រូវបានដាក់បញ្ចូលជាបណ្តើរៗនៅក្នុងកម្មវិធីផ្តល់អាហារតាមសាលារៀនដែលគាំទ្រដោយកម្មវិធីស្បៀងអាហារពិភពលោក។

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៤ | សម្របសម្រួលការគាំទ្រផ្នែកបច្ចេកទេសនិងថវិកាសម្រាប់ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ ដើម្បីធានានូវតម្លាភាព ការបំពេញគ្នាទៅទៅមកនិងភាពបន្សុីគ្នានៃកម្មវិធី | - ចំនួននៃការបណ្តុះបណ្តាលសិក្ខាសាលាកិច្ចប្រជុំសម្របសម្រួលដែលបានធ្វើឡើង | 0 | ២ដង ក្នុងមួយឆ្នាំ | | NCN, DP | ២០២៧-២០២៨ |
| **គោលចំណងយុទ្ធសាស្ត្រទី២** : ជំរុញការប្រើប្រាស់អាហារដែលបញ្ចូលមីក្រូសារជាតិក្នុងយន្តការស្ថាប័ន និងកម្មវិធីគាំពារសង្គម ដើម្បីលើកកម្ពស់អាហារូបត្ថម្ភក្នុងចំណោមប្រជាជនគោលដៅ | | | | | | | |
| **លទ្ធផលសម្រេចបាន២.១** : អាហារដែលបញ្ចូលមីក្រូសារជាតិត្រូវបានប្រើប្រាស់តាមរយៈយន្តការស្ថាប័ន និងកម្មវិធីគាំពារសង្គម | | - ចំនួនកម្មវិធីគាំពារសង្គម ជំនួយសង្គ្រោះបន្ទាន់<br>- អាហារដែលបញ្ចូលមីក្រូសារជាតិដែលបានផ្តល់តាមស្ថាប័ន | 0 | ១ (ការផ្តល់អាហារតាមសាលារៀន ស្បៀងបម្រុងគ្រាមានអាសន្ន និងអាហារដ្ឋានតាមរោងចក្រ) | របាយការណ៍ប្រចាំឆ្នាំ | NCN, MOYES, NSPC, DP | |
| ១ | គាំទ្រការធ្វើសមាហរណកម្មអង្ករដែលបញ្ចូលមីក្រូសារជាតិទៅក្នុងកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍តាមស្ថានភាពជាក់ស្តែងនៃសង្គម-សេដ្ឋកិច្ច | - ចំនួនសាលារៀនដែលបានទទួលអង្ករបញ្ចូលមីក្រូសារជាតិក្រោម NHGSFP<br>- ចំនួនសិស្សដែលបានទទួលអង្ករបញ្ចូលមីក្រូសារជាតិក្រោម NHGSFP | 0 | អាស្រ័យលើស្ថានភាពជាក់ស្តែងនៃសង្គមសេដ្ឋកិច្ច | | MOYES, NSPC, DP | ២០២៥-២០២៨ |
| ២ | គាំទ្រនិងបង្កើនការប្រើប្រាស់អាហារនិងគ្រឿងផ្សំដែលបញ្ចូលមីក្រូសារជាតិដល់កម្មករនៅក្នុងឧស្សាហកម្មរោងចក្រ | - ចំនួនកម្មកររោងចក្រដែលបានទទួលអាហារដែលបញ្ចូលមីក្រូសារជាតិ | 0 | ស្ត្រី ៣០០ ០០០ នាក់ | | NCN, ក្រុមហ៊ុនឯកជន, DP | ២០២៥-២០២៨ |
| ៣ | គាំទ្រនិងបង្កើនការប្រើប្រាស់អាហារនិងគ្រឿងផ្សំដែលបញ្ចូលមីក្រូសារជាតិក្នុងទីផ្សារស្ថាប័នផ្សេងទៀតរួមមាន ប្រព័ន្ធស្បៀងបម្រុងកម្ពុជា ប្រព័ន្ធបម្រុងទុកអង្ករគ្រាមានអាសន្នរបស់ប្រទេសអាស៊ានបូកបី (APTERR) ស្របតាមតាមការប្តេជ្ញាចិត្ត N4G ឆ្នាំ២០២៥ | - បរិមាណអាហារដែលបញ្ចូលមីក្រូសារជាតិដែលបានផ្គត់ផ្គង់ (គិតជាតោន ក្នុងមួយកម្មវិធីនិងមុខទំនិញ) | 0 | ៣០០០ MT | | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, NCN, DP | ២០២៥-២០២៨ |

ទោះបីជាមានការរីកចម្រើន ក្នុងការផ្សព្វផ្សាយអំពីអាហារដែលបញ្ចូលមីក្រូសារជាតិក៏ដោយ ប៉ុន្តែការទទួលទានវិញនៅតែមានកម្រិត ដោយសារតែចំណុចខ្វះខាតផ្នែកបទប្បញ្ញត្តិ ការយល់ដឹងរបស់អ្នកផលិត អ្នកប្រើប្រាស់នៅមានកម្រិត និងខ្វះទីផ្សារ។ យុទ្ធសាស្ត្រដែលត្រូវបានបង្កើតឡើងតាមរយៈដំណើរការសហការគ្នារវាងក្រសួងនិងដៃគូអភិវឌ្ឍនានា មានគោលបំណងដោះស្រាយបញ្ហាប្រឈមទាំងនេះ តាមរយៈការបង្កើនការគាំទ្រទៅលើផ្នែកគោលនយោបាយ ពង្រឹងក្របខ័ណ្ឌស្ថាប័ន ជំរុញការចូលរួមពីវិស័យឯកជនក្នុងការពង្រឹងការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារនេះ។

## ៣- យុទ្ធសាស្ត្រជាតិ ស្តីពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ

### ៣.១- មូលដ្ឋានទស្សនាទាន

**យុទ្ធសាស្ត្រជាតិ ស្តីពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ (យ.ជ.ប.អ.) ឆ្នាំ២០២៥-២០៣០** ត្រូវបានរៀបចំឡើងក្នុងក្របខ័ណ្ឌទស្សនាទានប្រព័ន្ធស្បៀង (រូបភាព ៣.១) ដែលបង្ហាញអំពីទំនាក់ទំនងអន្តរកម្មនៃខ្សែច្រវាក់ផ្គត់ផ្គង់អាហារ បរិយាកាសអាហារ កត្តាបុគ្គល និងឥរិយាបថអ្នកប្រើប្រាស់។ វិធីសាស្ត្រផ្អែកលើប្រព័ន្ធនេះ ធានាថាសសរស្តម្ភយុទ្ធសាស្ត្រទាំងអស់នៃយុទ្ធសាស្ត្រនេះ ត្រូវបានបំពេញបន្ថែមនិងមានដំណើរការស្របគ្នា ដើម្បីពង្រឹងកម្មវិធីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារដែលមានស្រាប់និងថ្មី រួមចំណែកដល់ការលើកកម្ពស់គុណភាពរបបអាហារ ធ្វើឱ្យប្រសើរឡើងនូវលទ្ធផលអាហារូបត្ថម្ភ និងជំរុញការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចក្នុងរយៈពេលវែង។

យុទ្ធសាស្ត្រនេះត្រូវបានដាក់មូលដ្ឋានលើសសរស្តម្ភសំខាន់ៗចំនួនប្រាំពីរ ដែលសសរស្តម្ភនីមួយៗ ផ្តោតលើទិដ្ឋភាពសំខាន់ៗនៃប្រព័ន្ធស្បៀង ខណៈដែលគាំទ្រដោយកត្តាអន្តរវិស័យមួយចំនួនដូចជាហិរញ្ញប្បទាន ការកសាងសមត្ថភាព ការតាមដានត្រួតពិនិត្យ ការវាយតម្លៃ និងការសិក្សា។ កត្តាជំរុញទាំងនេះ ធានាថាយុទ្ធសាស្ត្រនេះមានធនធានគ្រប់គ្រាន់ផ្អែកលើភស្តុតាងនិងភាពបត់បែនបានដែលជួយសម្រួលដល់ការកែលម្អជាបន្តបន្ទាប់និងធានានិរន្តរភាពរយៈពេលវែង។

តាមរយៈការបន្សីសសរស្តម្ភទាំងនេះជាមួយនឹងក្របខ័ណ្ឌប្រព័ន្ធស្បៀង យុទ្ធសាស្ត្រនេះបានអនុម័តឱ្យប្រើប្រាស់វិធីសាស្ត្រគ្រប់ជ្រុងជ្រោយ និង បែបសម្របសម្រួលដើម្បីធ្វើឱ្យល្អប្រសើរឡើង នូវការអនុវត្តការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ និងដោះស្រាយបញ្ហាកង្វះមីក្រូសារជាតិ។ យុទ្ធសាស្ត្រនេះ ប្រើប្រាស់ការប្រាស្រ័យសកម្មរវាងខ្សែច្រវាក់ផ្គត់ផ្គង់បរិស្ថានស្បៀង និងឥរិយាបថអ្នកប្រើប្រាស់ដើម្បីដោះស្រាយបញ្ហាប្រឈម និងឧបសគ្គពីផ្នែកខាងផ្គត់ផ្គង់ ផ្នែកតម្រូវការ និងបរិយាកាសអំណោយផលដើម្បីកសាងកម្មវិធីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារដែលរឹងមាំ មាននិរន្តរភាព និងប្រកបដោយបរិយាបន្ន ដោយមិនត្រឹមតែបង្កើនលទ្ធផលអាហារូបត្ថម្ភប៉ុណ្ណោះទេថែមទាំងពង្រឹងមូលធនមនុស្ស និងពន្លឿនភាពរីកចម្រើនផ្នែកសង្គម និងសេដ្ឋកិច្ចផងដែរ។

ផ្ដល់លទ្ធផលប្រកបដោយគុណភាពប្រសិទ្ធភាពសម្រាប់អាហារូបត្ថម្ភ សុខភាព និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។




**រូបភាព ៣.២** : ក្របខ័ណ្ឌយុទ្ធសាស្ត្រ **យ.ជ.ប.អ.** ២០២៥ - ២០៣០

ចំណុចស្នូលនៃក្របខ័ណ្ឌនេះមានសសរស្ដម្ភយុទ្ធសាស្ត្រចំនួនប្រាំពីរ រួមមាន៖ ១)អភិបាលកិច្ច ២)ជំរុញការប្រើប្រាស់ក្នុងយន្តការស្ថាប័ន និងកម្មវិធីគាំពារសង្គម ៣)បង្កើនការផលិតអាហារដែលបញ្ចូលមីក្រូសារជាតិ ៤)បង្កើតបរិយាកាសអំណោយផលនិងរចនាសម្ព័ន្ធលើកទឹកចិត្តធុរកិច្ច ៥)ពង្រឹងបទប្បញ្ញត្តិនិងក្របខ័ណ្ឌគតិយុត្ត ៦)បង្កើនការយល់ដឹងនិងជំរុញតម្រូវការអ្នកប្រើប្រាស់ និង ៧)ហិរញ្ញប្បទាន ដែលសសរស្ដម្ភនីមួយៗដោះស្រាយទិដ្ឋភាពផ្សេងៗគ្នានៃប្រព័ន្ធស្បៀង។ ជារួមសសរស្ដម្ភយុទ្ធសាស្ត្រទាំងប្រាំពីរនេះ ជាដំណោះស្រាយក្នុងគ្រប់ដំណាក់កាលទាំងអស់នៃប្រព័ន្ធស្បៀង ពោលគឺខ្សែច្រវាក់ផ្គត់ផ្គង់អាហារ បរិស្ថានស្បៀង កត្តាបុគ្គល និងឥរិយាបថអ្នកប្រើប្រាស់។ សសរស្ដម្ភទាំងនេះដោះស្រាយបញ្ហាផ្នែកផ្គត់ផ្គង់ ផ្នែកតម្រូវការ និងបរិយាកាសអំណោយផល រួមទាំងក្របខ័ណ្ឌបទប្បញ្ញត្តិ ដែលត្រូវបានគាំទ្រដោយកត្តាជំរុញអន្តរវិស័យ ដូចជាការពង្រឹងសមត្ថភាព ការតាមដានត្រួតពិនិត្យការវាយតម្លៃ ការសិក្សា ជាដើម។ ទិដ្ឋភាពទូទៅនៃគោលបំណងយុទ្ធសាស្ត្រ និងសកម្មភាពស្នូលមានបង្ហាញនៅក្នុងតារាង (៣.១) ខាងក្រោម៖

**តារាង ៣.១** : ទិដ្ឋភាពទូទៅនៃគោលបំណងនិងធាតុចេញនៃសសរស្តម្ភយុទ្ធសាស្ត្រនីមួយៗ

| សសរស្តម្ភយុទ្ធសាស្ត្រ | គោលបំណងយុទ្ធសាស្ត្រ | លទ្ធផលសម្រេចបាន |
|---|---|---|
| អភិបាលកិច្ច | **SO1**- ពង្រឹងអភិបាលកិច្ច កិច្ចសហការ និងសមត្ថភាពរបស់ក្រសួងស្ថាប័នពាក់ព័ន្ធសម្រាប់ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ | **RO1.1**- អភិបាលកិច្ច កិច្ចសហការ និងសមត្ថភាពសម្រាប់ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារត្រូវបានពង្រឹង |
| តម្រូវការក្នុងក្របខ័ណ្ឌស្ថាប័ន និងកម្មវិធីគាំពារសង្គម | **SO2**- ជំរុញការប្រើប្រាស់អាហារដែលបញ្ចូលមីក្រូសារជាតិក្នុងយន្តការស្ថាប័ន និងកម្មវិធីគាំពារសង្គមដើម្បីលើកកម្ពស់អាហារូបត្ថម្ភក្នុងចំណោមក្រុមប្រជាជនគោលដៅ | **RO2.1**- អាហារដែលបញ្ចូលមីក្រូសារជាតិត្រូវបានប្រើប្រាស់តាមរយៈយន្តការស្ថាប័ននិងកម្មវិធីគាំពារសង្គម |
| ផលិតកម្មអាហារដែលបញ្ចូលមីក្រូសារជាតិ | **SO3**- បង្កើនការផលិតអាហារដែលមានសុវត្ថិភាពនិងអាហារដែលបញ្ចូលមីក្រូសារជាតិឱ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការរួមទាំងអំបិល ទឹកត្រី ទឹកស៊ីអ៊ីវ អង្ករ និងផលិតផលផ្សេងទៀត | **RO3.1**- ពិនិត្យវាយតម្លៃទិដ្ឋភាពអាហារទូទៅនិងកំណត់រផលិតផលអាហារដែលសមស្របផ្សេងទៀតសម្រាប់បញ្ចូលមីក្រូសារជាតិ<br>**RO3.2**- បរិយាកាសអំណោយផលសម្រាប់ការផលិតអាហារដែលបញ្ចូលមីក្រូសារជាតិឱ្យកាន់តែមានគុណភាពរួមទាំងការប្រើប្រាស់សមាសធាតុមីក្រូសារជាតិលាយស្រេច (Premix) ត្រូវបានពង្រឹង<br>**RO3.3**- ការផលិតអាហារដែលបញ្ចូលមីក្រូសារជាតិត្រូវបានពង្រីកវិសាលភាពតាមរយៈការពង្រឹងសមត្ថភាពផលិតរបស់អ្នកផលិតអាហារដែលបញ្ចូលមីក្រូសារជាតិ |
| បរិយាកាសអំណោយផល និងការលើកទឹកចិត្តធុរកិច្ច | **SO4**- បង្កើតបរិយាកាសអំណោយផលនិងរចនាសម្ព័ន្ធលើកទឹកចិត្តធុរកិច្ចក្នុងការវិនិយោគក្នុងវិស័យអាហារដែលបញ្ចូលមីក្រូសារជាតិ | **RO4.1**- រចនាសម្ព័ន្ធលើកទឹកចិត្តនៃការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារត្រូវបានបង្កើតឡើង ដើម្បីលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជនបានកាន់តែច្រើន |

| | | |
|---|---|---|
| | | **RO4.2**- ការជំរុញទីផ្សារកាន់តែល្អប្រសើរសម្រាប់អាហារដែលបញ្ចូលមីក្រូសារជាតិ |
| ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ | **SO5**- ពង្រឹងបទប្បញ្ញត្តិនិងក្របខ័ណ្ឌគតិយុត្ត លើអាហារដែលបញ្ចូលមីក្រូសារជាតិនៅកម្រិតឧស្សាហកម្ម និងទីផ្សារ ដើម្បីធានាគុណភាពសុវត្ថិភាពនិងការពារសិទ្ធិអ្នកបរិភោគជាសាធារណៈ | **RO5.1**- ក្របខ័ណ្ឌច្បាប់ និង បទប្បញ្ញត្តិសម្រាប់ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារត្រូវបានពង្រឹង<br>**RO5.2**- ការអនុលោមតាមស្តង់ដា និងបទប្បញ្ញត្តិនៃការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារក្នុងវិស័យឧស្សាហកម្មនិងទីផ្សារត្រូវបានពង្រឹង<br>**RO5.3**- សមត្ថភាពរបស់ភាគីឯករាជ្យទីបីក្នុងស្រុក ដែលអាចបញ្ជាក់ ផ្ទៀងផ្ទាត់គុណភាពនិងកម្រិតអនុលោមភាពត្រូវបានពង្រឹង |
| ការយល់ដឹងរបស់អ្នកប្រើប្រាស់ និងការបង្កើតតម្រូវការ | **SO6**- បង្កើនការយល់ដឹងនិងជំរុញតម្រូវការអ្នកប្រើប្រាស់សម្រាប់អាហារដែលបញ្ចូលមីក្រូសារជាតិ | **RO6.1**-ការយល់ដឹងរបស់សាធារណជនអំពីអាហារដែលបញ្ចូលមីក្រូសារជាតិត្រូវបានលើកកម្ពស់<br>**RO6.2**- យុទ្ធសាស្ត្រផ្សព្វផ្សាយទីផ្សារសង្គមត្រូវបានបង្កើតឡើង និងអនុវត្ត |
| ហិរញ្ញប្បទាន | **SO7**- ផ្តល់ហិរញ្ញប្បទានសម្រាប់អនុវត្តកម្មវិធីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ | **RO7.1**- ហិរញ្ញប្បទានសម្រាប់អនុវត្តកម្មវិធីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារត្រូវបានវិភាជន៍ និងធានាក្នុងការផ្តល់ |

## ៣.៥- ផ្នែកអាទិភាព

### ៣.៥.១- ផ្នែកអាទិភាពនៃសកម្មភាព

នេះជាផ្នែកមួយនៃដំណើរការរៀបចំផែនការយុទ្ធសាស្ត្រ ដើម្បីកំណត់រកសកម្មភាពសំខាន់ៗដែលចាំបាច់សម្រាប់ការអនុវត្តសកម្មភាពទាំងនោះតាមដំណាក់កាលនីមួយៗ។ ការកំណត់សកម្មភាពនេះបានរៀបចំតាមរយៈការពិភាក្សាជាមួយភាគីពាក់ព័ន្ធដែលបានចូលរួមនានា ក្នុងអំឡុងសិក្ខាសាលាមួយនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០២៥ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ សិក្ខាសាលានេះមានគោលបំណងវាយតម្លៃការរួមចំណែកតាមវិស័យនីមួយៗ កំណត់រកបញ្ហាប្រឈមក្នុងការអនុវត្ត និងកំណត់អាទិភាពសកម្មភាពនានា សម្រាប់វិធីសាស្ត្ររួមបញ្ចូលនិងពហុវិស័យ ដើម្បីផ្លាស់ប្តូរប្រព័ន្ធស្បៀងព្រមទាំងផ្តល់ជាព័ត៌មានសម្រាប់ការអភិវឌ្ឍយុទ្ធសាស្ត្រហិរញ្ញប្បទាន និងសម្រាប់ផែនទីបង្ហាញផ្លូវអាហារដែលបានកែសម្រួលផងដែរ។ ដំណើរការនេះបានគូសបញ្ជាក់អំពីវិស័យសំខាន់ៗចំនួនបី ដែលបានក្លាយជាវិស័យអាទិភាពចម្បងសម្រាប់ការពង្រីកវិសាលភាពនៃការអនុវត្តកម្មវិធីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារក្នុងប្រទេសកម្ពុជា៖

- ការអនុម័តស្តង់ដាជាតិសម្រាប់អង្ករដែលបញ្ចូលមីក្រូសារជាតិ

- ការពង្រឹងសមត្ថភាពផលិតកម្ម
- ការអនុវត្តក្របខ័ណ្ឌច្បាប់ដែលបានកែសម្រួលនៅពេលបែងចែកទៅតាមសសរស្តម្ភយុទ្ធសាស្ត្រ។

ផ្នែកអាទិភាពខ្ពស់បំផុតនោះរួមមាន៖

- ក្របខ័ណ្ឌគតិយុត្ត និង បទប្បញ្ញត្តិ
- សមត្ថភាពផលិតកម្ម
- ជំរុញការប្រើប្រាស់ក្នុងយន្តការស្ថាប័ន

សសរស្តម្ភទាំងនេះនឹងណែនាំអំពីដំណាក់កាលដំបូងនៃការអនុវត្ត និងជាមូលដ្ឋានគ្រឹះសម្រាប់ការចូលរួមពហុវិស័យប្រកបដោយនិរន្តរភាព។

## ៣.៥.២- មធ្យោបាយក្នុងការពង្រីកវិសាលភាព

តម្រូវការទីផ្សារដែលការបញ្ជាទិញអាហារស្ថិតក្រោមការគ្រប់គ្រងដោយស្ថាប័នសាធារណៈ និងឯកជន គឺជាចំណុចផ្ដើមដ៏ល្អមួយសម្រាប់អាហារដែលបញ្ចូលមីក្រូសារជាតិ ព្រោះទីផ្សារនេះ អនុញ្ញាតឱ្យមានកិច្ចអន្តរាគមន៍គោលដៅចំពោះប្រជាជនងាយរងគ្រោះ (ដូចជាកុមារក្នុងវ័យសិក្សានិងស្ត្រីក្នុងវ័យបន្តពូជ) និងមានលក្ខណៈងាយស្រួលក្នុងការគ្រប់គ្រង។ ដោយមានការគាំទ្រការប្រើប្រាស់ថ្នាលកម្មវិធីដូចជាកម្មវិធីផ្ដល់អាហារតាមសាលារៀននិងអាហារដ្ឋានតាមរោងចក្រ យើងអាចដោះស្រាយបញ្ហាកង្វះអាហារូបត្ថម្ភបានភ្លាមៗ ថែមទាំងអាចបង្កើនតម្រូវការមានស្ថិរភាពសម្រាប់អាហារដែលបញ្ចូលមីក្រូសារជាតិនៅលើទីផ្សារដែលបានគ្រប់គ្រង។ វិធីសាស្ត្រតាមលំដាប់លំដោយនេះត្រូវបានប្រទេសភាគច្រើនក្នុងតំបន់និងសកលលោកបន្តអនុវត្ត[8] [9] ដោយមិនត្រឹមតែពង្រឹងប្រព័ន្ធនៃការបញ្ចូលមីក្រូសារជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជំរុញការវិនិយោគពីវិស័យឯកជនបន្តិចម្តងៗ ដោយកំណត់មូលដ្ឋានគ្រឹះក្នុងការពង្រីកវិសាលភាពនៃការបញ្ចូលមីក្រូសារជាតិ ជាកិច្ចអន្តរាគមន៍អាហារូបត្ថម្ភសម្រាប់ប្រជាជនគ្រប់រូបតាមរយៈទីផ្សារសេរីនាពេលអនាគត។ រូបភាពទី៣.៣ : បង្ហាញអំពីមធ្យោបាយដែលបានស្នើឡើងដើម្បីពង្រីកវិសាលភាពអនុវត្ត និងអនុម័តដោយភាគីពាក់ព័ន្ធដែលមានវត្តមាននៅក្នុងសិក្ខាសាលា។




**រូបភាព ៣.៣** : មធ្យោបាយក្នុងការពង្រីកវិសាលភាពក្នុងការអនុវត្ត

[8] **World Food Programme. 2023.** *[Journey of Rice Fortification in India].* Available at: https://docs.wfp.org/api/documents/WFP-0000153426/download/

[9] **World Food Programme. 2022.** *[Harnessing market forces to combat anaemia through rice fortification in Peru].* Available at: https://docs.wfp.org/api/documents/WFP-0000140804/download/

ពាក់ព័ន្ធគួរត្រូវបានពង្រឹងឱ្យកាន់តែមានមានភាពច្បាស់លាស់និងទំនួលខុសត្រូវខ្ពស់ ក្នុងការអនុវត្តកម្មវិធីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ។

### ៣.៦.១.១- លទ្ធផលសម្រេចបាន១.១ : អភិបាលកិច្ច កិច្ចសហការ និងសមត្ថភាពសម្រាប់ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារត្រូវបានពង្រឹង

**សកម្មភាពស្នូលរួមមាន៖**

១- ពិនិត្យនិងកែសម្រួលរចនាសម្ព័ន្ធសម្របសម្រួលសម្រាប់ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ និង ពិចារណាលើការបញ្ចូល អ.ជ.ម.អ (NSCFF) និងអ.ជ.ល.ក.អ (NSCIDD) រួមគ្នា។

២- ពិនិត្យ ពង្រឹងទំនួលខុសត្រូវ និងដែនយុត្តាធិការរបស់ក្រសួងជំនាញពាក់ព័ន្ធតាមខ្សែច្រវាក់ផ្គត់ផ្គង់ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ។

៣- ដោយផ្អែកលើរចនាសម្ព័ន្ធសម្របសម្រួលដែលបានកែសម្រួល នឹងនាំឱ្យអាចធានាបាននូវការពង្រឹងសមត្ថភាពឱ្យបានគ្រប់គ្រាន់ ហើយធនធានចាំបាច់និងត្រូវបានបែងចែកសម្រាប់ការអនុវត្តភារកិច្ចតាមស្ថាប័នរៀងខ្លួន។

៤- សម្របសម្រួលការគាំទ្រផ្នែកបច្ចេកទេសនិងថវិកាសម្រាប់ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ ដើម្បីធានានូវតម្លាភាព ការបំពេញឱ្យគ្នាទៅវិញទៅមក និងការបន្សុំកម្មវិធីរួមគ្នាដើម្បីទទួលបានលទ្ធផលកាន់តែប្រសើរឡើង។

### ៣.៦.២- គោលបំណងយុទ្ធសាស្ត្រទី២ : ជំរុញការប្រើប្រាស់អាហារដែលបញ្ចូលមីក្រូសារជាតិក្នុងយន្តការស្ថាប័ន និងកម្មវិធីគាំពារសង្គម ដើម្បីលើកកម្ពស់អាហារូបត្ថម្ភក្នុងចំណោមប្រជាជនគោលដៅ

បច្ចុប្បន្ន តម្រូវការអាហារដែលបញ្ចូលមីក្រូសារជាតិក្នុងប្រទេសកម្ពុជានៅមានកម្រិត។ កម្មវិធីជាតិគាំពារសង្គមនិងថ្នាលយន្តការស្ថាប័ន រួមមានកម្មវិធីផ្តល់អាហារតាមសាលារៀន សេវាផ្តល់ម្ហូបអាហារសម្រាប់កម្មកររោងចក្រ សិស្សសាលារដ្ឋ ឯកជន និងមន្ទីរពេទ្យ គឺជាទីផ្សារដែលមានសក្តានុពលសម្រាប់បង្កើនតម្រូវការនិងជំរុញការផលិតអាហារដែលបញ្ចូលមីក្រូសារជាតិ។ ការជំរុញការប្រើប្រាស់យន្តការស្ថាប័នទាំងនេះនឹងជួយបង្កើតស្ថិរភាពតម្រូវការសម្រាប់អាហារដែលបញ្ចូលមីក្រូសារជាតិ ព្រមទាំងជំរុញការវិនិយោគលើផលិតកម្មផលិតផលដែលបញ្ចូលមីក្រូសារជាតិ ដោះស្រាយបញ្ហាកង្វះមីក្រូសារជាតិ និងលើកកម្ពស់អាហារូបត្ថម្ភក្នុងចំណោមប្រជាជនងាយរងគ្រោះ ដូចជាកុមារក្នុងវ័យសិក្សា កម្មកររោងចក្រ ជាដើម។

### ៣.៦.២.១- លទ្ធផលសម្រេចបាន២.១ : អាហារដែលបញ្ចូលមីក្រូសារជាតិ ត្រូវបានប្រើប្រាស់តាមរយៈយន្តការស្ថាប័ននិងកម្មវិធីគាំពារសង្គម

**សកម្មភាពស្នូលរួមមាន៖**

១- គាំទ្រការធ្វើសមាហរណកម្ម ការប្រើប្រាស់អង្ករដែលបញ្ចូលមីក្រូសារជាតិទៅក្នុងកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ (NHGSFP) តាមស្ថានភាពជាក់ស្តែងនៃសង្គម សេដ្ឋកិច្ច និងស្របតាមការប្តេជ្ញាចិត្តស្តីពីអាហារូបត្ថម្ភដើម្បីកំណើន (N4G) ឆ្នាំ២០២៥។

២- គាំទ្រការធ្វើសមាហរណកម្មអាហារនិងគ្រឿងផ្សំដែលបញ្ចូលមីក្រូសារជាតិទៅដល់កម្មករ កម្មការិនីដែលធ្វើការក្នុងឧស្សាហកម្មរោងចក្រ។
៣- ពង្រឹងនិងពង្រីកការប្រើប្រាស់អាហារដែលបញ្ចូលមីក្រូសារជាតិ ទៅក្នុងទីផ្សារស្ថាប័នផ្សេងទៀត រួមមាន ប្រព័ន្ធស្បៀងបម្រុងកម្ពុជា ប្រព័ន្ធបម្រុងទុកអង្ករក្នុងគ្រាមានអាសន្នរបស់ប្រទេសអាស៊ានបូកបី (APTERR) ស្របតាមការប្តេជ្ញាចិត្ត ស្តីពីអាហារូបត្ថម្ភដើម្បីកំណើន N4G ឆ្នាំ២០២៥។
៤- ពិនិត្យពិចារណាលើលទ្ធកម្ម និងការផ្តល់ស្បៀងអាហារនិងគ្រឿងផ្សំដែលបញ្ចូលមីក្រូសារជាតិ ទៅក្នុងស្ថាប័នរដ្ឋនិងឯកជន ដែលផ្តល់អាហារឆ្អិននិងអាហារសម្រន់ ដូចជានៅតាមមន្ទីរពេទ្យ អាហារដ្ឋាននៅសាកលវិទ្យាល័យ កន្ត្រកម្ហូបអាហារ (food baskets) និងកម្មវិធីប្រើប្រាស់ប័ណ្ណប្តូរអាហារ (voucher programmes)។

### ៣.៦.៣- គោលបំណងយុទ្ធសាស្ត្រទី៣ : បង្កើនការផលិតអាហារដែលមានសុវត្ថិភាព និងអាហារដែលបញ្ចូលមីក្រូសារជាតិឱ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការរួមទាំងអំបិល ទឹកត្រី ទឹកស៊ីអ៊ីវ អង្ករ និងផលិតផលផ្សេងទៀត

ដើម្បីសម្រេចបាននូវគោលបំណងយុទ្ធសាស្ត្រនេះ កិច្ចអន្តរាគមន៍ជាបន្តបន្ទាប់ខាងក្រោម ត្រូវបានស្នើឡើង ដោយចាប់ផ្តើមពីការស្វែងយល់អំពីស្ថានភាពនៃបញ្ហាកង្វះមីក្រូសារជាតិ បញ្ហាប្រឈម និងចន្លោះខ្វះខាតក្នុងការផលិតអាហារដែលបញ្ចូលមីក្រូសារជាតិ និងការបង្កើតកិច្ចអន្តរាគមន៍ដែលសមស្រប ដើម្បីបង្កើនបរិយាកាសអំណោយផលនិងពង្រឹងសមត្ថភាពផលិតកម្មរបស់អ្នកផលិតអាហារដែលបញ្ចូលមីក្រូសារជាតិឱ្យកាន់តែទូលំទូលាយ។

#### ៣.៦.៣.១- លទ្ធផលសម្រេចបាន៣.១ : ពិនិត្យវាយតម្លៃទិដ្ឋភាពអាហារទូទៅនិងកំណត់រកផលិតផលអាហារដែលសមស្របផ្សេងទៀតសម្រាប់បញ្ចូលមីក្រូសារជាតិ

ការធ្វើផែនទីទូទាំងប្រទេសអំពីផលិតផលអាហារ និងការស្រង់ទិន្នន័យអំពីបញ្ហាកង្វះមីក្រូសារជាតិ នឹងត្រូវធ្វើឡើងរួមជាមួយនឹងការពិនិត្យឡើងវិញគ្រប់ជ្រុងជ្រោយ អំពីសមត្ថភាពបច្ចេកទេសរបស់អ្នកផលិតអាហារដែលបញ្ចូលមីក្រូសារជាតិ។ លទ្ធផលនៃការធ្វើផែនទីនិងការត្រួតពិនិត្យសមត្ថភាពទាំងនេះ គឺជាធាតុចូលក្នុងការបង្កើន និងអនុវត្តកម្មវិធីពង្រឹងសមត្ថភាពប្រកបដោយប្រសិទ្ធភាព ដើម្បីពង្រីកផលិតកម្មអាហារដែលបញ្ចូលមីក្រូសារជាតិ។

**សកម្មភាពស្នូលរួមមានៈ**

១- អនុវត្តការគូសផែនទីអំពីផលិតផលអាហារដែលមានសក្តានុពលនិងការស្រង់ទិន្នន័យលើបញ្ហាកង្វះមីក្រូសារជាតិ។
២- ធ្វើការពិនិត្យឱ្យបានស៊ីជម្រៅនិងគ្រប់ជ្រុងជ្រោយទៅលើបច្ចេកទេស សមត្ថភាព ផលិតកម្មរបស់ឧស្សាហកម្មម្ហូបអាហារ និងរោងចក្រផលិតអាហារដែលបញ្ចូលមីក្រូសារជាតិ ដើម្បីកំណត់នូវចន្លោះខ្វះខាតនានាដូចជា បច្ចេកវិទ្យា ស្តង់ដាប្រតិបត្តិ ចំណេះដឹង ការអនុវត្តរបស់បុគ្គលិក បញ្ហាប្រឈម និងតម្រូវការសម្រាប់ការគាំទ្រដើម្បីពង្រីកផលិតកម្មអាហារដែលបញ្ចូលមីក្រូសារជាតិ។

### ៣.៦.៣.២- លទ្ធផលសម្រេចបាន៣.២ : បរិយាកាសអំណោយផលសម្រាប់ការផលិតអាហារដែលបញ្ចូលមីក្រូសារជាតិឱ្យកាន់តែមានគុណភាព រួមទាំងការប្រើប្រាស់ សមាសធាតុមីក្រូសារជាតិលាយស្រេច (Premix) ត្រូវបានពង្រឹង

ភាពងាយរកបាននិងការទទួលបាននូវសមាសធាតុមីក្រូសារជាតិលាយស្រេចដែលមានគុណភាពក្នុងតម្លៃសមរម្យ គឺជាឧបសគ្គមួយសម្រាប់ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ ដោយសារតែការចំណាយខ្ពស់និងនីតិវិធីនាំចូលស្មុគស្មាញ។ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ យុទ្ធសាស្ត្រនេះក៏បានគិតគូរដល់ការសម្រួលដំណើរការនាំចូលនិងប្រមូលផ្តុំតម្រូវការទិញសារធាតុមីក្រូសារជាតិលាយស្រេច ដើម្បីកាត់បន្ថយបន្ទុកលទ្ធកម្មនិងតម្លៃ។ ការសិក្សាស្ដីពីលទ្ធភាពនៃការផលិតគ្រាប់/ម្សៅវីតាមីនលាយស្រេចក្នុងស្រុក ក៏ត្រូវបានស្នើឡើងក្នុងការអនុវត្តផងដែរ។

**សកម្មភាពស្នូលរួមមាន៖**

១- កាត់បន្ថយឧបសគ្គនិងរយៈពេលនៃដំណើរការលទ្ធកម្មសម្រាប់សមាសធាតុមីក្រូសារជាតិលាយស្រេច (រួមទាំងគ្រាប់អង្ករមីក្រូសារជាតិ) រវាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងពាណិជ្ជកម្ម និងក្រសួងសុខាភិបាល។

២- ធ្វើការវាយតម្លៃសិក្សាលទ្ធភាព (បច្ចេកទេស ហិរញ្ញវត្ថុ ជាដើម) សម្រាប់ផលិតកម្មគ្រាប់អង្ករមីក្រូសារជាតិក្នុងស្រុក។

៣- សម្រួលនិងបញ្ជាក់ឱ្យបានច្បាស់លាស់អំពីដំណើរការចុះបញ្ជីឧស្សាហកម្ម និង ផលិតផលអាហារដែលបញ្ចូលមីក្រូសារជាតិ។ ចំពោះក្រសួងពាណិជ្ជកម្ម អនុវត្តភារកិច្ចតួនាទីពាក់ព័ន្ធនឹងផលិតផលនាំចូលដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។ ចំពោះក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ អនុវត្តភារកិច្ចតួនាទីពាក់ព័ន្ធនឹងផលិតផលដែលបញ្ចូលមីក្រូសារជាតិទូទៅនៅក្នុងកម្រិតផលិតកម្ម។ ចំណែកក្រសួងសុខាភិបាលអនុវត្តភារកិច្ចតួនាទីពាក់ព័ន្ធនឹងឱសថ/ផលិតផលអាហារបំប៉នផលិតផលអាហារព្យាបាល (RUTF)។

### ៣.៦.៣.៣- លទ្ធផលសម្រេចបាន៣.៣ : ការផលិតអាហារដែលបញ្ចូលមីក្រូសារជាតិត្រូវបានពង្រីកវិសាលភាពតាមរយៈការពង្រឹងសមត្ថភាពផលិតរបស់អ្នកផលិតអាហារដែលបញ្ចូលមីក្រូសារជាតិ

អ្នកផលិតអំបិលអ៊ីយ៉ូដ ទឹកត្រី ទឹកស៊ីអ៊ីវមានជាតិដែក និងអង្ករដែលបញ្ចូលមីក្រូសារជាតិប្រឈមមុខនឹងបញ្ហាជាច្រើនក្នុងការពង្រីកទំហំផលិតកម្មរបស់ពួកគេ។ ទាំងនេះរួមមាន ចំណេះដឹងអំពីនីតិវិធីនាំចូលសមាសធាតុមីក្រូសារជាតិលាយស្រេចនៅមានកម្រិត ដំណើរការផលិតកម្ម ជំនាញបច្ចេកទេស និងប្រព័ន្ធធានាគុណភាពផ្ទៃក្នុង ព្រមទាំងប្រព័ន្ធត្រួតពិនិត្យគុណភាពនៅមានកម្រិត។ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ ការពង្រឹងសមត្ថភាពនឹងត្រូវបានផ្តល់ជូនចំពោះអ្នកផលិតម្ចាស់រោងម៉ាស៊ីននិងម្ចាស់សិប្បកម្ម ដើម្បីអាចឱ្យពួកគេបំពេញតម្រូវការទីផ្សាររបស់អាហារដែលបញ្ចូលមីក្រូសារជាតិបាន។ ការនាំចូលនូវសមាសធាតុមីក្រូសារជាតិលាយស្រេច គឺជាការទទួលខុសត្រូវរបស់វិស័យឯកជន ដោយមានការជួយសម្របសម្រួលលើនីតិវិធីនានាពីវិស័យសាធារណៈ។

**សកម្មភាពស្នូលរួមមាន៖**

១- ផ្តល់ការពង្រឹងសមត្ថភាពជាក់ស្តែងដល់អ្នកផលិត (សិប្បកម្ម រោងម៉ាស៊ីនជាដើម) ដើម្បីបញ្ចូលមីក្រូសារជាតិក្នុងអាហារឱ្យស្របតាមបរិមាណដែលទីផ្សារត្រូវការរួមទាំងសមាសធាតុដូចខាងក្រោមសម្រាប់មុខទំនិញនីមួយៗ៖

១.១- អង្ករដែលបញ្ចូលមីក្រូសារជាតិ : ដំណើរការនាំចូលសមាសធាតុមីក្រូសារជាតិលាយស្រេចនិងនីតិវិធីនៃការបញ្ចេញទំនិញពីគយនិងរដ្ឋាករ ឧបករណ៍ និងបរិក្ខារ គោលការណ៍ណែនាំផលិតកម្ម គោលការណ៍ណែនាំអំពីការធានានិងគ្រប់គ្រងគុណភាព (QA &QC) ផ្ទៃក្នុង។

១.២- អំបិលអ៊ីយ៉ូដ : ដំណើរការនាំចូលម្សៅអ៊ីយ៉ូដ (Premix) និងនីតិវិធីនៃការបញ្ចេញទំនិញពីគយនិងរដ្ឋាករសម្រាប់ប៉ូតាស្យូមអ៊ីយ៉ូដាយ (KI) និងប៉ូតាស្យូមអ៊ីយ៉ូដាត (KIO៣) ឧបករណ៍បរិក្ខារ គោលការណ៍ណែនាំក្នុងការផលិតនិងគោលការណ៍ណែនាំអំពីការធានានិងគ្រប់គ្រងគុណភាព (QA &QC) ផ្ទៃក្នុង។

១.៣- ទឹកត្រី ទឹកស៊ីអ៊ីវមានជាតិដែក : ដំណើរការនាំចូលម្សៅជាតិដែក (Premix) និងនីតិវិធីនៃការបញ្ចេញទំនិញពីគយនិងរដ្ឋាករ (សូដ្យូម អាយរ៉ន អ៊ីឌីធីអេ (NaFeEDTA) ឬអាយរ៉នស៊ុលហ្វាត និងសាយត្រេត (FeSO4+Citrate) ឧបករណ៍ បរិក្ខារ គោលការណ៍ណែនាំក្នុងការផលិត និងគោលការណ៍នាំអំពីការធានានិងគ្រប់គ្រងគុណភាព (QA &QC) ផ្ទៃក្នុង។

២- សិក្សាពីការអនុវត្តល្អបំផុត និងពង្រីកការប្រើប្រាស់ផលិតផលដែលបញ្ចូលមីក្រូសារជាតិតាមរយៈការបង្កើតភាពជាដៃគូនិងទស្សនកិច្ចសិក្សា។

៣- ស្វែងរកការគាំទ្របច្ចេកវិទ្យាការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារថ្មីៗដែលស្របទៅនឹងបរិបទក្នុងស្រុក។

៤- រៀបចំផែនទីអ្នកផ្តល់សេវាបច្ចេកទេស និងសម្របសម្រួលទំនាក់ទំនងរវាងអ្នកផ្តល់សេវា និងអ្នកផលិតអាហារដែលបញ្ចូលមីក្រូសារជាតិសម្រាប់សេវាបណ្តុះបណ្តាល។

### **៣.៦.៤- គោលចំណងយុទ្ធសាស្ត្រទី៤** : បង្កើតបរិយាកាសអំណោយផល និងរចនាសម្ព័ន្ធលើកទឹកចិត្តធុរកិច្ចក្នុងការវិនិយោគលើវិស័យអាហារដែលបញ្ចូលមីក្រូសារជាតិ

ដើម្បីធានាបាននូវនិរន្តរភាព និងវិសាលភាពពង្រីកគំនិតផ្តួចផ្តើមនៃការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ បរិយាកាសអំណោយផលដល់ធុរកិច្ច ត្រូវតែបង្កើតឡើងដើម្បីលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជន។ ការបង្កើតគោលនយោបាយគាំទ្រ កម្មវិធីលើកទឹកចិត្ត និងការផ្សារភ្ជាប់ទីផ្សារនឹងជួយជំរុញការវិនិយោគ និងនិរន្តរភាពរយៈពេលវែងដើម្បីផលិតអាហារដែលបញ្ចូលមីក្រូសារជាតិ។

#### **៣.៦.៤.១- លទ្ធផលសម្រេចបាន៤.១** : រចនាសម្ព័ន្ធលើកទឹកចិត្តនៃការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារត្រូវបានបង្កើតឡើង ដើម្បីលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជន

**សកម្មភាពស្នូលរួមមាន៖**

១- សិក្សាសមិទ្ធិលទ្ធភាពបង្កើតកម្មវិធីលើកទឹកចិត្តដើម្បីលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជននិងពង្រឹងកម្មវិធីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ (ឧទាហរណ៍ ការលើកលែង

| | | | | | | | |
|---|---|---|---|---|---|---|---|
| មីក្រូសារជាតិឱ្យកាន់តែមានគុណភាព និងពង្រឹងការប្រើប្រាស់សមាសធាតុមីក្រូសារជាតិលាយស្រេច (Premix) | | ពង្រីកការផលិតអាហារដែលបញ្ចូលមីក្រូសារជាតិដែលបានអនុវត្ត | | | | | |
| ១ | កាត់បន្ថយឧបសគ្គនិងដំណើរការលទ្ធកម្មដ៏យូរ សម្រាប់សមាសធាតុមីក្រូសារជាតិលាយស្រេច (រួមទាំងគ្រាប់អង្ករដែលបញ្ចូលមីក្រូសារជាតិ) រវាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យានិងនវានុវត្តន៍ ក្រសួងពាណិជ្ជកម្ម និងក្រសួងសុខាភិបាល | - ចំនួនឯកសារណែនាំដើម្បីកាត់បន្ថយឧបសគ្គនិងលទ្ធកម្មសមាសធាតុមីក្រូសារជាតិលាយស្រេចដែលបានបង្កើតឡើង | 0 | ១ | | MISTI, MoC, MoH, DP | ២០២៥-២០២៦ |
| ២ | ធ្វើការវាយតម្លៃសិក្សាលទ្ធភាព (បច្ចេកទេស ហិរញ្ញវត្ថុជាដើម) សម្រាប់ផលិតកម្មគ្រាប់អង្ករដែលបញ្ចូលមីក្រូសារជាតិក្នុងស្រុក | - ចំនួននៃការវាយតម្លៃលទ្ធភាពដែលបានធ្វើឡើង | 0 | ១ | | NCN, DP | ២០២៩-២០៣០ |
| ៣ | ចំពោះក្រសួងពាណិជ្ជកម្ម អនុវត្តភារកិច្ចតួនាទីពាក់ព័ន្ធនឹង ផលិតផលនាំចូលដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ ចំពោះក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ អនុវត្តភារកិច្ចតួនាទីពាក់ព័ន្ធនឹងផលិតផលដែលបញ្ចូលមីក្រូសារជាតិទូទៅនៅក្នុងកម្រិតលិតកម្ម | - ចំនួននៃដំណើរការចុះឈ្មោះដែលបានពិនិត្យនិងធ្វើបច្ចុប្បន្នកម្ម | 0 | ១ | | MISTI, MoC, MoH, DP | ២០២៧-២០២៨ |
| **លទ្ធផលសម្រេចបាន៣.៣** : ការផលិតអាហារដែលបញ្ចូលមីក្រូសារជាតិត្រូវបានពង្រីកវិសាលភាពតាមរយៈការពង្រឹងសមត្ថភាពផលិតរបស់អ្នកផលិតអាហារដែលបញ្ចូលមីក្រូសារជាតិ | | - បរិមាណអំបិលអ៊ីយ៉ូដដែលបានផលិត (MT) បរិមាណអង្ករដែលបញ្ចូលមីក្រូសារជាតិដែលបានផលិត (MT)/បរិមាណទឹកត្រី ទឹកស៊ីអ៊ីវមានជាតិដែកដែលបានផលិត(លីត្រ) | 0 | | | NCN, MISTI, DP | |
| | | - ចំនួនឯកសារណែនាំដែលបានបង្កើតឡើង | 0 | ៦ | | MISTI | |

ពន្ធ និង/ឬការឧបត្ថម្ភធនសម្រាប់ការនាំចូលសម្ភារៈបរិក្ខារបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ សារធាតុមីក្រូសារជាតិលាយស្រេច និងគ្រាប់អង្ករមីក្រូសារជាតិ (FRKs)។

២- សម្របសម្រួលដល់ការទទួលបានជំនួយថវិកាឥតសំណង និង/ឬ កម្ចីការប្រាក់ទាបពីធនាគាររដ្ឋ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ (IFIs) (ឧទាហរណ៍ ធនាគារ ARDB ធនាគារ SME IFC ជាដើម)។

៣- ផ្តល់ការលើកទឹកចិត្តនិងការឧបត្ថម្ភធនដល់អ្នកផលិត ចំពោះការអនុលោមតាមស្តង់ដាការលើកកម្ពស់ផលិតកម្ម និងគុណភាពនៃអាហារដែលបញ្ចូលមីក្រូសារជាតិដែលមានតម្លៃសមរម្យ ក្នុងគោលដៅបង្កើនការប្រកួតប្រជែងនៃផលិតផលជាតិ។

៤- សម្របសម្រួលភាពជាដៃគូរវាងវិស័យសាធារណៈ (សាកលវិទ្យាល័យ វិទ្យាស្ថានស្រាវជ្រាវ ។ល។) និងវិស័យឯកជន ដើម្បីផ្តល់ការលើកទឹកចិត្តដល់ការស្រាវជ្រាវ ការអភិវឌ្ឍលើបច្ចេកវិទ្យានិងនវានុវត្តន៍ ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ និងការរួមចំណែកចេញថ្លៃចំណាយវិនិយោគជាមុនដែលចាំបាច់។

### ៣.៦.៤.២- លទ្ធផលសម្រេចបាន៤.២ : ការផ្សារភ្ជាប់ទីផ្សារកាន់តែល្អប្រសើរសម្រាប់អាហារដែលបញ្ចូលមីក្រូសារជាតិ

**សកម្មភាពស្នូលរួមមាន៖**

១- ធ្វើការស្ទង់មតិដើម្បីស្វែងយល់អំពីទីផ្សារលក់រាយ និង សក្តានុពលនៃតម្រូវការអាហារដែលបញ្ចូលមីក្រូសារជាតិ (ដូចជាបរិមាណ វិញ្ញឹកភាព ដែនគ្របដណ្តប់ ជាដើម)។

២- ជួយគាំទ្រក្នុងការផ្គូផ្គងអាជីវកម្មនៃអាហារដែលបញ្ចូលមីក្រូសារជាតិ ជាមួយនឹងយន្តការលទ្ធកម្មសាធារណៈ។

៣- ស្វែងរកឱកាសសម្រាប់ការនាំចេញអង្ករដែលបញ្ចូលមីក្រូសារជាតិទៅប្រទេសក្នុងតំបន់។

៤- ជួយសម្រួលដល់ការរៀនសូត្រ ការផ្លាស់ប្តូរបទពិសោធ ភាពជោគជ័យ ឧបសគ្គ រវាងក្រុមហ៊ុនឬអាជីវករនៅក្នុងវិស័យអាហារដែលបញ្ចូលមីក្រូសារជាតិ។

៥- បង្កើតករណីសិក្សាដែលបង្ហាញអំពីភាពជោគជ័យនៃការធ្វើអាជីវកម្ម និងការវិនិយោគលើការផលិតអាហារដែលបញ្ចូលមីក្រូសារជាតិ។

៦- រៀបចំវគ្គបណ្តុះបណ្តាលតម្រង់ទិសដល់អ្នកគ្រប់គ្រងឧស្សាហកម្មម្ហូបអាហារជាន់ខ្ពស់អំពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារនិងសារៈសំខាន់របស់វា។

### ៣.៦.៥- គោលចំណងយុទ្ធសាស្ត្រទី៥ : ពង្រឹងបទប្បញ្ញត្តិនិងក្របខ័ណ្ឌគតិយុត្តលើអាហារដែលបញ្ចូលមីក្រូសារជាតិនៅកម្រិតឧស្សាហកម្មនិងទីផ្សារដើម្បីធានាគុណភាព សុវត្ថិភាព និងការពារសិទ្ធិអ្នកបរិភោគជាសាធារណៈ

ក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិនៃកម្មវិធីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារដែលកំពុងអនុវត្តនៅក្នុងប្រទេសកម្ពុជានៅមានលក្ខណៈបែកខ្ញែក និងមានចំណុចខ្វះខាតមួយចំនួន។ ការពង្រឹងលើកិច្ចអនុវត្តច្បាប់និងបទប្បញ្ញត្តិនៅតែមិនទាន់មានលក្ខណៈគ្រប់គ្រាន់ ដូចជានៅតែមានអាហារដែលបញ្ចូលមីក្រូសារជាតិដែលមិនអនុលោមតាមស្តង់ដាជាតិបន្តចរាចរនៅក្នុងទីផ្សារ ថ្វីបើមានស្តង់ដា

បទប្បញ្ញត្តិបច្ចេកទេសក៏ដោយ។ ការពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិនិងយន្តការអនុវត្ត ពិតជាសំខាន់ក្នុងការធានាបាននូវអនុលោមភាពនិងប្រសិទ្ធភាព។

### ៣.៦.៥.១- លទ្ធផលសម្រេចបាន៥.១ : ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិសម្រាប់ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារត្រូវបានពង្រឹង

ប្រទេសកម្ពុជាមិនទាន់មានគោលនយោបាយជាតិ ស្តីពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារនៅឡើយទេ។ បើគ្មានគោលនយោបាយរួម ដែលគូសបញ្ជាក់អំពីទិសដៅជាយុទ្ធសាស្ត្រទេ ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ នឹងមិនត្រូវបានផ្តល់អាទិភាពថាជាកិច្ចអន្តរាគមន៍របស់រាជរដ្ឋាភិបាលដ៏សំខាន់ ដើម្បីលុបបំបាត់បញ្ហាកង្វះមីក្រូសារជាតិនោះទេ។ ច្បាប់ស្តីពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ គឺផ្តោតលើកម្មវិធីការបញ្ចូលមីក្រូសារជាតិជាកាតព្វកិច្ច និងមាននៅក្នុងច្បាប់មួយចំនួនដើម្បីអនុវត្តបទប្បញ្ញត្តិ ស្តីពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារប្រកបដោយប្រសិទ្ធភាព ក្របខ័ណ្ឌនីតិប្បញ្ញត្តិ ដែលចែងអំពីលក្ខខណ្ឌតម្រូវនេះត្រូវតែមានភាពច្បាស់លាស់ចំពោះគ្រប់ភាគីពាក់ព័ន្ធទាំងអស់ជាពិសេសចំពោះអ្នកផលិតអាហារដែលបញ្ចូលមីក្រូសារជាតិ។ បទប្បញ្ញត្តិស្តង់ដានិងគោលការណ៍ណែនាំបច្ចុប្បន្ន នឹងត្រូវពិនិត្យនិងវិភាគដើម្បីកំណត់ភាពមិនស៊ីគ្នានិងផ្នែកត្រួតស៊ីគ្នា។ បទប្បញ្ញត្តិ ស្តីពីការបញ្ចូលមីក្រូសារជាតិក្នុងអង្ករត្រូវតែអនុម័ត។

**សកម្មភាពស្នូលរួមមានៈ**

១- ពិនិត្យនិងវិភាគបទប្បញ្ញត្តិស្តង់ដានិងគោលការណ៍ណែនាំដែលមានស្រាប់ ដើម្បីកំណត់រកចំណុចខ្វះខាតនិងឱកាស ដើម្បីកំណត់ទិសដៅខាងមុខចំពោះមុខទំនិញមានជាអាទិ៍ (១)អំបិលអ៊ីយ៉ូដ (២)ទឹកត្រីទឹកស៊ីអ៊ីវមានជាតិដែក (៣)អង្ករដែលបញ្ចូលមីក្រូសារជាតិ (៤)ផលិតផលអាហារដែលមានសក្តានុពលផ្សេងទៀត។

២- កែសម្រួលក្របខ័ណ្ឌនីតិប្បញ្ញត្តិ រួមទាំងការកំណត់យ៉ាងច្បាស់អំពីមុខងារ និងភារកិច្ចរបស់ស្ថាប័ន នីមួយៗដែលពាក់ព័ន្ធនឹងការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ។

៣- រៀបចំសិក្ខាសាលាផ្សព្វផ្សាយ អំពីក្របខ័ណ្ឌបទប្បញ្ញត្តិដែលបានកែសម្រួលសម្រាប់អំបិលអ៊ីយ៉ូដ ទឹកត្រី ទឹកស៊ីអ៊ីវមានជាតិដែក និងអង្ករដែលបញ្ចូលមីក្រូសារជាតិ ព្រមទាំងអាហារដែលបញ្ចូលមីក្រូសារជាតិសក្តានុពលផ្សេងទៀត រួមទាំងបទប្បញ្ញត្តិស្តង់ដានិងគោលការណ៍ណែនាំត្រួតពិនិត្យ។

៤- បង្កើតឬពិនិត្យឡើងវិញនូវបទប្បញ្ញត្តិសម្រាប់ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហាររួមទាំងប្រភេទផលិតផលអាហារ ប្រភេទនិងកម្រិតនៃមីក្រូសារជាតិ ការដាក់ស្លាកសញ្ញា និងការបញ្ជាក់ព័ត៌មានអំពីអាហារូបត្ថម្ភ ការណែនាំអំពីការប្រើប្រាស់សម្រាប់អាហារដែលបញ្ចូលមីក្រូសារជាតិ និងការធ្វើទីផ្សារលើអាហារដែលបញ្ចូលមីក្រូសារជាតិ។

៥- បង្កើតនិងអនុម័តស្តង់ដាសម្រាប់អង្ករដែលបញ្ចូលមីក្រូសារជាតិ។

៦- រចនានិងអនុវត្តកម្មវិធីពង្រឹងសមត្ថភាព សម្រាប់ស្ថាប័នរាជរដ្ឋាភិបាលទទួលបន្ទុកត្រួតពិនិត្យគុណភាព អាហារដែលបញ្ចូលមីក្រូសារជាតិ។

៧- ពង្រឹងការអនុវត្តបទប្បញ្ញត្តិដែលតម្រូវឱ្យផលិតផលអាហារនាំចូល ត្រូវអនុលោមតាមស្តង់ដានៃការបញ្ចូលមីក្រូសារជាតិក្នុងស្រុក។

### ៣.៦.៥.២- លទ្ធផលសម្រេចបាន៥.២ : ការអនុលោមតាមស្តង់ដានិងបទប្បញ្ញត្តិនៃការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារក្នុងវិស័យឧស្សាហកម្មនិងទីផ្សារត្រូវបានពង្រឹង

ការអនុលោមតាមបទប្បញ្ញត្តិនិងស្តង់ដា នៅតែមិនទាន់ស៊ីចង្វាក់គ្នានិងមិនទាន់គ្រប់គ្រាន់។ វិធានការសម្របត្រូវតែធ្វើឡើង ដើម្បីបង្កើនអនុលោមភាពទាំងនៅទីតាំងផលិតកម្មនិងកម្រិតទីផ្សារ។ ផែនការនិងនីតិវិធីអធិការកិច្ចច្បាស់លាស់ត្រូវតែបង្កើតឡើង ហើយសមត្ថភាពរបស់មន្ត្រីអធិការកិច្ចផ្លូវការដែលមានទំនួលខុសត្រូវ ក៏ដូចជាស្ថាប័នពាក់ព័ន្ធក៏ត្រូវតែពង្រឹង។

**សកម្មភាពស្នូលរួមមាន៖**

១- ពិនិត្យសមត្ថភាព និងកែសម្រួលនីតិវិធីអធិការកិច្ច សម្រាប់អាហារដែលបញ្ចូលមីក្រូសារជាតិ កម្រិតផលិតកម្ម ការចែកចាយ និងទីផ្សារ។
២- បង្កើត និង អនុវត្តផែនការសកម្មភាពអធិការកិច្ចលើការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារថ្នាក់ជាតិ រួមមានប៉ារ៉ាម៉ែត្រច្បាស់លាស់ស្តីពី រំញឹកភាព ការយកសំណាកគំរូ ការគ្របដណ្តប់ទីតាំងភូមិសាស្ត្រជាដើម សម្រាប់អាហារដែលបញ្ចូលមីក្រូសារជាតិនីមួយៗ ដើម្បីពង្រឹងអនុលោមភាពក្នុងវិស័យឧស្សាហកម្មនិងទីផ្សារ រួមទាំងវិធានការចំពោះការមិនអនុលោមតាមច្បាប់។
៣- ពង្រឹងសមត្ថភាពរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ក្នុងការត្រួតពិនិត្យទីតាំងផលិតកម្មអាហារដែលបញ្ចូលមីក្រូសារជាតិពាក់ព័ន្ធទាំងអស់។
៤- ពង្រឹងសមត្ថភាពរបស់ក្រសួងពាណិជ្ជកម្មក្នុងការត្រួតពិនិត្យអាហារដែលបញ្ចូលមីក្រូសារជាតិនៅកម្រិតទីផ្សារ។
៥- កំណត់អត្តសញ្ញាណអ្នកទទួលបន្ទុក បង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មានស្តង់ដា (MIS) ប្រព័ន្ធរាយការណ៍ និងចែករំលែករបាយការណ៍ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីទទួលយកការគ្រប់គ្រង និងការសម្រេចចិត្តផ្លូវច្បាប់ដោយផ្អែកលើលទ្ធផលរកឃើញ និងផ្តល់អនុសាសន៍។
៦- បង្កើតប្រព័ន្ធស្វ័យរាយការណ៍អំពីការធានានិងគ្រប់គ្រងគុណភាព (QA/QC) សម្រាប់អ្នកផលិតអង្ករ អំបិល ទឹកត្រី ទឹកស៊ីអ៊ីវ និងអាហារមូលដ្ឋានផ្សេងទៀតដែលបញ្ចូលមីក្រូសារជាតិដែលត្រូវដាក់ជូនស្ថាប័នពាក់ព័ន្ធ។
៧- បង្កើតយន្តការផ្តល់មតិត្រឡប់ពីអ្នកប្រើប្រាស់ ដើម្បីកំណត់អត្តសញ្ញាណចំណុចមិនអនុលោមតាមច្បាប់ និងបង្កើតវិធានការឆ្លើយតបសមស្រប។

### ៣.៦.៥.៣- លទ្ធផលសម្រេចបាន៥.៣ : សមត្ថភាពរបស់ភាគីឯករាជ្យទីបីក្នុងស្រុកដែលអាចបញ្ជាក់ផ្ទៀងផ្ទាត់គុណភាពនិងកម្រិតអនុលោមភាពត្រូវបានពង្រឹង

សមត្ថភាពរបស់មន្ទីរពិសោធន៍ ក្នុងការវិភាគមីក្រូសារជាតិនៃអាហារដែលបញ្ចូលមីក្រូសារជាតិនៅមានកម្រិត។ ទាំងនាយកដ្ឋានមន្ទីរពិសោធន៍របស់អគ្គនាយកដ្ឋាន ក.ប.ប. និងមន្ទីរពិសោធន៍ជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (NISTI) មានសមត្ថភាពក្នុងការវិភាគសារធាតុអ៊ីយ៉ូដ និងជាតិដែក ប៉ុន្តែមិនអាចវិភាគវីតាមីននិងសារជាតិរ៉ែខនិជផ្សេងទៀតនោះទេ។

ក្រុមហ៊ុនផលិតអាហារដែលបញ្ចូលមីក្រូសារជាតិ និងសហគ្រាសធុនតូចនិងមធ្យម (SMEs) បានបញ្ជូនសំណាកទៅមន្ទីរពិសោធន៍ក្រៅប្រទេស សម្រាប់ការធ្វើតេស្តវិភាគរកវីតាមីននិងសារជាតិ

៣- បង្កើតនិងអនុវត្តយុទ្ធនាការលើកកម្ពស់ការយល់ដឹង (ដូចជា និមិត្តសញ្ញា អ្នកមានឥទ្ធិពល ការរៀបចំនិងធ្វើសារដែលមាននៅលើស្លាកសញ្ញាអាហារូបត្ថម្ភ និង ការអះអាងអំពីសុខភាព) អំពីអត្ថប្រយោជន៍របស់អាហារដែលបញ្ចូលមីក្រូសារជាតិ ដើម្បីផ្សារភ្ជាប់ជាមួយការអនុវត្តកម្មវិធីចែកចាយផលិតផលបញ្ចូលមីក្រូសារជាតិ។

**៣.៦.៦.២- លទ្ធផលសម្រេចបាន៦.២** : យុទ្ធសាស្ត្រផ្សព្វផ្សាយទីផ្សារសង្គមត្រូវបានបង្កើតនិងអនុវត្ត

យុទ្ធសាស្ត្រទីផ្សារសង្គមដែលផ្អែកលើភស្តុតាង គួរតែត្រូវបានបង្កើតឡើងនិងអនុវត្តឱ្យបានឆាប់រហ័ស នៅក្នុងក្របខ័ណ្ឌនៃការអនុវត្តយុទ្ធសាស្ត្រជាតិ ស្តីពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ ឆ្នាំ២០២៥-២០៣០។

**សកម្មភាពស្នូលរួមមាន៖**

១- ធ្វើការស្រាវជ្រាវប្រមូលព័ត៌មាន រួមទាំងការអង្កេតទៅលើចំណេះដឹង ឥរិយាបថ និងការអនុវត្ត (KAPs) ឆន្ទៈរបស់អ្នកប្រើប្រាស់ក្នុងការចំណាយនិងការសិក្សាពាក់ព័ន្ធផ្សេងទៀត។
២- បង្កើតយុទ្ធសាស្ត្រទីផ្សារសង្គមផ្អែកលើភស្តុតាង ដើម្បីបង្កើនការយល់ដឹងអំពីអត្ថប្រយោជន៍នៃការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ។
៣- បង្កើតនិងអនុវត្តយុទ្ធនាការទីផ្សារសង្គមពហុបណ្តាញ ដោយប្រើប្រាស់វិធីសាស្ត្រផ្លាស់ប្តូរឥរិយាបថសង្គមដោយផ្អែកលើការស្ទង់មតិទីផ្សារនិងអ្នកប្រើប្រាស់សម្រាប់ផលិតផលអាហារដែលបញ្ចូលមីក្រូសារជាតិនីមួយៗ។

**៣.៦.៧- គោលបំណងយុទ្ធសាស្ត្រទី៧** : ការធានាការផ្តល់ហិរញ្ញប្បទានសម្រាប់ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ

កង្វះធនធានហិរញ្ញវត្ថុពីរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងវិស័យឯកជន គឺជាឧបសគ្គចម្បងក្នុងការអនុវត្តការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ ដែលចាំបាច់ត្រូវធ្វើការដោះស្រាយជាលក្ខណៈប្រព័ន្ធនិងប្រកបដោយនិរន្តរភាព។ បច្ចុប្បន្នរាជរដ្ឋាភិបាលកម្ពុជាមិនមានខ្ទង់ថវិកាជាក់លាក់សម្រាប់សកម្មភាពកម្មវិធីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារនោះទេ ហើយកិច្ចខិតខំប្រឹងប្រែងនៃការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារគឺពឹងផ្អែកយ៉ាងខ្លាំងលើជំនួយដៃគូអភិវឌ្ឍនិងអង្គការសង្គមស៊ីវិលនៅឡើយ។

**៣.៦.៧.១- លទ្ធផលសម្រេចបាន៧.១** : ហិរញ្ញប្បទានសម្រាប់អនុវត្តការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារត្រូវបានវិភាជន៍

**សកម្មភាពស្នូលរួមមាន៖**

១- រៀបចំថវិកាចំណាយរបស់ផែនការសកម្មភាពដែលមានចែងក្នុងយុទ្ធសាស្ត្រនេះ។
២- បង្កើតយុទ្ធសាស្ត្រហិរញ្ញប្បទាន ដោយផ្តល់អាទិភាពលើសកម្មភាព ឬយន្តការដែលមានភាពជាក់លាក់ជាមុនក្នុងការពង្រីកវិសាលភាពរបស់អាហារដែលបញ្ចូលមីក្រូសារជាតិ។
៣- បង្កើតវិធីសាស្ត្រតស៊ូមតិដើម្បីកៀរគរការគាំទ្រ និងប្រមូលធនធានទៅតាមផែនការ។

សកម្មភាពទាំងអស់ខាងលើ មានលក្ខណៈគ្រប់ជ្រុងជ្រោយនិងត្រូវបានរៀបចំឡើងដើម្បីពង្រីកវិសាលភាពនៃការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារប្រកបដោយនិរន្តរភាពនិងប្រសិទ្ធភាព។ ដើម្បី

សម្រេចបាននូវសកម្មភាពទាំងនេះត្រូវការការប្តេជ្ញាចិត្ត ការសម្របសម្រួល និងការវិនិយោគដ៏រឹងមាំពីរាជរដ្ឋាភិបាល ព្រមទាំងការគាំទ្រ និងការចូលរួមយ៉ាងសកម្មពីដៃគូអភិវឌ្ឍន៍និងវិស័យឯកជន។ តារាងទី៣.៣ : បង្ហាញអំពីបញ្ជីសកម្មភាពអាទិភាពតាមប្រភេទផលិតផលអាហារដែលបញ្ចូលមីក្រូសារជាតិ។

**តារាង ៣.៣** : ផែនកសកម្មភាពអាទិភាពទៅតាមអាហារដែលបញ្ចូលមីក្រូសារជាតិនីមួយៗ

| ផលិតផល | ក្រុមគោលដៅ | ផែនកសកម្មភាពអាទិភាព | ស្ថាប័នដឹកនាំ | ដៃគូ |
|---|---|---|---|---|
| • អង្ករ | • កុមារក្នុងវ័យសិក្សា<br>• ស្ត្រីក្នុងវ័យបន្តពូជ<br>• ប្រជាជនទាំងមូល | • គាំទ្រការធ្វើសមាហរណកម្មអង្ករដែលបញ្ចូលមីក្រូសារជាតិទៅក្នុងកម្មវិធីផ្តល់អាហារពេលព្រឹកតាមសាលារៀនតាមស្ថានភាពជាក់ស្តែងនៃសង្គម សេដ្ឋកិច្ច<br>• បង្កើតនិងអនុម័តស្តង់ដាសម្រាប់អង្ករដែលបញ្ចូលមីក្រូសារជាតិ<br>• ពិនិត្យលទ្ធភាពនិងជំរុញការប្រើប្រាស់អង្ករដែលបញ្ចូលមីក្រូសារជាតិទៅក្នុងកម្មវិធីគាំពារសង្គមផ្សេងៗតាមទិដ្ឋភាពជាក់ស្តែងនៃសង្គម-សេដ្ឋកិច្ច<br>• កសាងសមត្ថភាពវិស័យឯកជន ដើម្បីផលិតអង្ករដែលបញ្ចូលមីក្រូសារជាតិប្រកបដោយសុវត្ថិភាពនិងគុណភាពខ្ពស់<br>• កសាងសមត្ថភាពរបស់រាជរដ្ឋាភិបាល និងវិស័យឯកជនដើម្បីធានាបាននូវការអនុលោមតាមស្តង់ដា<br>• បង្កើនចំណេះដឹងដល់អ្នកផលិត អ្នកប្រើប្រាស់និងបញ្ចូលទៅក្នុងកម្មវិធីសិក្សា<br>• ពង្រឹងការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃប្រកបដោយគុណភាពនិងប្រសិទ្ធភាព។ | MoEYS, NSPC, NCN, MOP | WFP, UNICEF, FAO, WHO |
| • អំបិល | • កុមារក្នុងវ័យសិក្សា<br>• ប្រជាជនទាំងមូល | • ជំរុញការប្រើប្រាស់អំបិលអ៊ីយ៉ូដទៅក្នុងកម្មវិធីផ្តល់អាហារពេលព្រឹកតាមសាលារៀន<br>• កសាងសមត្ថភាព វិស័យឯកជនដើម្បីផលិតអំបិលអ៊ីយ៉ូដប្រកបដោយសុវត្ថិភាពនិងគុណភាពខ្ពស់ | NCN, MOP | WFP, UNICEF, FAO, WHO |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ផលិតកម្មអាហារដែលបញ្ចូលមីក្រូសារជាតិពាក់ព័ន្ធទាំងអស់ | | | | | | |
| ៤ | ពង្រឹងសមត្ថភាពរបស់ក្រសួងពាណិជ្ជកម្មក្នុងការត្រួតពិនិត្យអាហារដែលបញ្ចូលមីក្រូសារជាតិនៅកម្រិតទីផ្សារ | - ចំនួនមន្ត្រីអធិការកិច្ច ក្រសួងពាណិជ្ជកម្មដែលត្រូវបានបណ្តុះបណ្តាលលើនីតិវិធីអធិការកិច្ច | 0 | ១២៥ | របាយការណ៍ប្រចាំឆ្នាំ | NCN, MoC, DP | ២០២៧-២០៣០ |
| ៥ | កំណត់អត្តសញ្ញាណអ្នកទទួលបន្ទុកនិងបង្កើតប្រព័ន្ធព័ត៌មានគ្រប់គ្រងស្តង់ដា (MIS) និងប្រព័ន្ធរាយការណ៍ចែករំលែករបាយការណ៍ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីទទួលយកការគ្រប់គ្រងនិងការសម្រេចចិត្តផ្លូវច្បាប់ដោយផ្អែកលើលទ្ធផលរកឃើញនិងផ្តល់អនុសាសន៍ | - អ្នកទទួលខុសត្រូវនិងប្រព័ន្ធរាយការណ៍តាមស្តង់ដាត្រូវបានបង្កើតឡើង | 0 | ១ | របាយការណ៍ប្រចាំឆ្នាំ<br>ប្រព័ន្ធរាយការណ៍ត្រូវបានបង្កើតឡើង | NCN, DP | ២០២៧-២០៣០ |
| ៦ | បង្កើតប្រព័ន្ធស្វ័យរាយការណ៍អំពីការធានានិងគ្រប់គ្រងគុណភាព (QA/QC) សម្រាប់អ្នកផលិតអង្ករ និងអំបិលដែលបញ្ចូលមីក្រូសារជាតិដែលត្រូវដាក់ជូនស្ថាប័នពាក់ព័ន្ធ | - ប្រព័ន្ធស្វ័យរាយការណ៍ដែលបានបង្កើតឡើង<br>- ចំនួនអ្នកផលិតដែលបានដាក់របាយការណ៍ QA/QC ដោយខ្លួនឯងតាមរយៈប្រព័ន្ធដែលបានបង្កើតឡើង | 0<br>0 | ១<br>១០ | របាយការណ៍ប្រចាំឆ្នាំ | NCN, MISTI, MoC | ២០២៧-២០៣០ |
| ៧ | បង្កើតយន្តការផ្តល់មតិត្រឡប់ពីអ្នកប្រើប្រាស់ដើម្បីកំណត់អត្តសញ្ញាណ ចំណុចមិនអនុលោមតាមច្បាប់ និងបង្កើតវិធានការឆ្លើយតបសមស្រប | - យន្តការផ្តល់មតិត្រឡប់ពីអ្នកប្រើត្រូវបានបង្កើតឡើង និងមានដំណើរការ | 0 | ១ | របាយការណ៍ប្រចាំឆ្នាំ<br>មតិត្រលប់អ្នកប្រើប្រាស់ដែលបានបង្កើតឡើង | NCN, MoC, DP | ២០២៧-២០៣០ |

| | | | | |
|---|---|---|---|---|
| | | • កសាងសមត្ថភាពរបស់រាជរដ្ឋាភិបាល (NSCFF) និងវិស័យឯកជន ដើម្បីធានាបាននូវការអនុលោមតាមស្តង់ដាបទប្បញ្ញត្តិច្បេកទេស<br>• បង្កើនចំណេះដឹងដល់អ្នកផលិត អ្នកប្រើប្រាស់ និងបញ្ចូលទៅក្នុងកម្មវិធីសិក្សា<br>• ពង្រឹងការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃប្រកបដោយគុណភាពនិងប្រសិទ្ធភាព | | |
| • ទឹកត្រី ទឹកស៊ីអ៊ីវ | • សិស្សសាលា<br>• ប្រជាជនទាំងមូល | • ជំរុញការប្រើប្រាស់ទឹកត្រីនិងទឹកស៊ីអ៊ីវមានជាតិដែកទៅក្នុងកម្មវិធីផ្តល់អាហារពេលព្រឹកតាមសាលារៀន<br>• កសាងសមត្ថភាព វិស័យឯកជនដើម្បីផលិតទឹកត្រី ទឹកស៊ីអ៊ីវដែលបញ្ចូលជាតិដែកប្រកបដោយសុវត្ថិភាពនិងគុណភាព<br>• កសាងសមត្ថភាពរបស់រាជរដ្ឋាភិបាល (NSCFF) និងវិស័យឯកជន ដើម្បីធានាបាននូវការអនុលោមតាមស្តង់ដាបទប្បញ្ញត្តិបច្ចេកទេស<br>• បង្កើនចំណេះដឹងដល់អ្នកផលិត អ្នកប្រើប្រាស់ និងបញ្ចូលទៅក្នុងកម្មវិធីសិក្សា<br>• ពង្រឹងការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃប្រកបដោយគុណភាពនិងប្រសិទ្ធភាព។ | NCN, MOP | DP |

## ៤- ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃសម្រាប់គណនេយ្យភាព និងការសិក្សា

### ៤.១- ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ដើម្បីតាមដានវឌ្ឍនភាពនៃសកម្មភាពដែលមានចែងក្នុងយុទ្ធសាស្ត្រជាតិ ស្តីពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ (២០២៥-២០៣០) ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលម្អិត (M&E) ត្រូវបានបង្កើតឡើង (**សូមមើលឧបសម្ព័ន្ធ៥.១**)។ សូចនាករត្រូវបានបង្កើតឡើងសម្រាប់លទ្ធផលធាតុសម្រេចបាន និងសកម្មភាពស្នូលដែលបានរៀបរាប់នៅក្នុងជំពូកទី៤ នៃយុទ្ធសាស្ត្រនេះ។ ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ និងធានាថាសូចនាករស្តង់ដាត្រូវបានត្រួតពិនិត្យ និងវាស់វែងជាទៀងទាត់ ដើម្បីវាយតម្លៃលើការគ្រប់ដណ្តប់កិច្ចអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាព។

ប្រព័ន្ធប្រមូលទិន្នន័យនិងការវិភាគថ្នាក់ជាតិ ត្រូវបានបង្កើតឡើងនិងភ្ជាប់ជាមួយប្រព័ន្ធព័ត៌មានអាហារូបត្ថម្ភជាតិដែលមានស្រាប់។ អ្នកទទួលបន្ទុកថ្នាក់ជាតិ នឹងត្រូវកំណត់អត្តសញ្ញាណ រចនាសម្ព័ន្ធសម្របសម្រួលដែលមានស្រាប់នឹងត្រូវបានពិនិត្យឡើងវិញ ដើម្បីបង្កើនប្រសិទ្ធភាពនិងជួយលុបបំបាត់បញ្ហាប្រឈម ព្រមទាំងបញ្ហាបគំនិតផ្តួចផ្តើមនៃការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ។

របាយការណ៍ត្រួតពិនិត្យប្រចាំឆ្នាំ ត្រូវបានរៀបចំដោយអនុគណៈកម្មការជាតិបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារនៅកម្ពុជា ក្រុមប្រឹក្សាជាតិស្តីពីអាហារូបត្ថម្ភជាតិនៃក្រសួងផែនការ និង ភាគីពាក់ព័ន្ធដទៃទៀតរបស់រាជរដ្ឋាភិបាល។ របាយការណ៍ទាំងនេះនឹងដើរតួនាទីជាមូលដ្ឋានសម្រាប់ធ្វើការត្រួតពិនិត្យប្រចាំឆ្នាំលើផែនការយុទ្ធសាស្ត្រ កិច្ចអន្តរាគមន៍ និងថវិកា។ បទពិសោធទាំងនេះ នឹងត្រូវបានចងក្រងជាឯកសារសម្រាប់ប្រើប្រាស់ជាធាតុចូលផងដែរក្នុងការកែសម្រួលលើសកម្មភាពក្នុងយុទ្ធសាស្ត្រនេះ។

ក្រុមប្រឹក្សាជាតិស្តីពីអាហារូបត្ថម្ភជាតិ ដឹកនាំដោយក្រសួងផែនការ នឹងចេញគោលការណ៍ណែនាំក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដោយផ្អែកលើសូចនាករ ដើម្បីបញ្ជ្រាបបញ្ហាអាហារូបត្ថម្ភក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ក្រសួង ស្ថាប័ន និងផែនការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអាចអនុវត្តបានប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធិភាព។ ក្រសួងស្ថាប័នត្រូវចូលរួមសហការប្រកបដោយភាពបុរេសកម្ម សកម្ម និងការទទួលខុសត្រូវខ្ពស់ក្នុងការផ្តល់ធាតុចូលឱ្យបានគ្រប់ជ្រុងជ្រោយជូនក្រុមប្រឹក្សាជាតិស្តីពីអាហារូបត្ថម្ភជាតិដើម្បីរៀបចំរបាយការណ៍ **យុទ្ធសាស្ត្រជាតិ ស្តីពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ** (**យ.ជ.ប.អ.**) ឆ្នាំ២០២៥-២០៣០ ប្រចាំឆ្នាំ ពាក់កណ្តាលអាណត្តិ និងចុងអាណត្តិជូនរាជរដ្ឋាភិបាល។ ក្រសួងស្ថាប័នពាក់ព័ន្ធត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកាឱ្យស្របតាមលទ្ធភាពនៃថវិកាជាតិ និងមានការវិភាគបញ្ហាអាហារូបត្ថម្ភក្នុងផែនការសកម្មភាពប្រចាំឆ្នាំរបស់ក្រសួងស្ថាប័ន។

## ៤.២- ការបង្កើតភស្តុតាងនិងការសិក្សា

លទ្ធផលនៃការសិក្សានិងប្រព័ន្ធព័ត៌មានប្រមូលទិន្នន័យត្រូវបានប្រើជាមូលដ្ឋានគ្រឹះដើម្បីបង្កើតភស្តុតាងនិងបទពិសោធសិក្សា និងដើម្បីផ្តល់ព័ត៌មានអំពីទិសដៅឆ្ពោះទៅមុខសម្រាប់គំនិតផ្តួចផ្តើមនៃការបញ្ចូលមីក្រូសារជាតិនៅក្នុងប្រទេសកម្ពុជា។ កិច្ចខិតខំប្រឹងប្រែងនេះត្រូវបានធ្វើឡើងតាមលទ្ធភាពដែលអាចធ្វើទៅបានដើម្បីបញ្ចូលការស្រាវជ្រាវពាក់ព័ន្ធនឹងការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ និងការបង្កើតភស្តុតាងទៅក្នុងកម្មវិធីអាហារូបត្ថម្ភដែលកំពុងអនុវត្តឬគំនិតផ្តួចផ្តើមផ្សេងទៀត។ សកម្មភាពសំខាន់មួយសម្រាប់ការអនុវត្តនេះ គឺជាការបញ្ចូលសំណួរស្តីពីការប្រើប្រាស់អាហារដែលបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារទៅក្នុងការអង្កេតថ្នាក់ជាតិ។

លើសពីនេះ ឱកាសក្នុងការសិក្សារៀនសូត្រពីប្រទេសផ្សេងៗ ក្នុងទម្រង់ជាដំណើរទស្សនកិច្ចសិក្សា ឬវេទិកាពាក់ព័ន្ធផ្សេងទៀតនឹងត្រូវបានពិនិត្យបន្ថែម។ រាល់ភស្តុតាងនិងបទពិសោធសិក្សាដែលបានបង្កើតឡើងក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ ត្រូវបានចែករំលែកជាមួយភាគីពាក់ព័ន្ធថ្នាក់ជាតិ ថ្នាក់ក្រោមជាតិនិងថ្នាក់តំបន់។

ដើម្បីធានាថាខ្លឹមសារនិងចំណេះដឹងនេះ ត្រូវបានរក្សាទុកនិងអាចចូលប្រើប្រាស់បានលើសពីអាយុកាលនៃគម្រោងនីមួយៗ ជាការណែនាំសូមបង្កើតទីតាំងទិន្នន័យថ្នាក់កណ្តាលមួយនៅក្រសួងផែនការ។ ឃ្លាំងទិន្នន័យនេះមានផ្ទុកនូវឯកសារសំខាន់ៗ ឧបករណ៍ និងទិន្នន័យ ដែលផ្តល់ជាឯកសារយោងសម្រាប់អនុវត្តសកម្មភាពជួយដល់ការសម្រេចចិត្តនិងអំណោយផលសម្រាប់បន្តលើការផ្លាស់ប្តូរនូវការអនុវត្តកម្មវិធី និងគោលនយោបាយនានា។

## ៥- ឧបសម្ព័ន្ធ

### ៥.១- ឧបសម្ព័ន្ធទី១ : ក្របខ័ណ្ឌយុទ្ធសាស្ត្រតាមដាន ត្រួតពិនិត្យ និងវាយតម្លៃសម្រាប់ឆ្នាំ២០២៥-២០៣០

| ល.រ. | សកម្មភាពស្នូល | សូចនាករ | ទិន្នន័យមូលដ្ឋាន | គោលដៅ | មធ្យោបាយផ្ទៀងផ្ទាត់ | ស្ថាប័នទទួលខុសត្រូវ | កាលវិភាគអនុវត្តន៍ |
|---|---|---|---|---|---|---|---|
| **គោលចំណងយុទ្ធសាស្ត្រទី១** : ពង្រឹងអភិបាលកិច្ច កិច្ចសហការ និងសមត្ថភាពរបស់ក្រសួងស្ថាប័នពាក់ព័ន្ធសម្រាប់កម្មវិធីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ | | | | | | | |
| **លទ្ធផលសម្រេចបាន១.១** : អភិបាលកិច្ច កិច្ចសហការ និងសមត្ថភាពសម្រាប់ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារត្រូវបានពង្រឹង | | | | | របាយការណ៍ប្រចាំឆ្នាំ | NCN, MISTI, MoC, MoH, DP | |
| ១ | ពិនិត្យនិងកែសម្រួលរចនាសម្ព័ន្ធសម្របសម្រួលសម្រាប់ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ និងពិចារណាលើការច្របាច់បញ្ចូលគ្នារវាង អ.ជ.ម.អ. និង អ.ជ.ល.ក.អ. | - ការបញ្ចប់និងការអនុម័តលើរចនាសម្ព័ន្ធសម្របសម្រួលដែលបានកែសម្រួល រួមទាំងតួនាទីនិងការទទួលខុសត្រូវច្បាស់លាស់ | មិនមាន | មាន | | NCN, DP | ២០២៥-២០២៦ |
| ២ | ពិនិត្យនិងពង្រឹងទំនួលខុសត្រូវ និង ដែនយុត្តាធិការរបស់ក្រសួងជំនាញពាក់ព័ន្ធតាមខ្សែច្រវាក់ផ្គត់ផ្គង់ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ | -អនុក្រឹត្យដែលបានកែសម្រួលឬលិខិតូបករណ៍ផ្លូវច្បាប់ដែលរៀបរាប់អំពីតួនាទី និងទំនួលខុសត្រូវរបស់ក្រសួងជំនាញក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារត្រូវបានអនុម័ត | មិនមាន | មាន | | MISTI, MoC, MoH, DP | ២០២៥-២០២៦ |
| ៣ | ដោយផ្អែកលើរចនាសម្ព័ន្ធសម្របសម្រួលដែលបានកែសម្រួល យើងអាចធានាបាននូវការពង្រឹងសមត្ថភាពឱ្យបានគ្រប់គ្រាន់ ហើយធនធានត្រូវបានបែងចែកសម្រាប់ការអនុវត្តតាមភារកិច្ច | - ចំនួនបុគ្គលិកដែលបានបណ្តុះបណ្តាល | 0 | ៣០នាក់ក្នុងមួយឆ្នាំ | | NCN, DP, MoC | ២០២៧-២០២៨ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៤ | ពិនិត្យនិងពិចារណាលើលទ្ធកម្ម និងការផ្តល់ស្បៀងអាហារ និងគ្រឿងផ្សំដែលបញ្ចូលមីក្រូសារជាតិទៅក្នុងស្ថាប័នរដ្ឋ និងឯកជន ដែលផ្តល់អាហារឆ្អិននិងអាហារសម្រន់ ដូចជានៅតាមមន្ទីរពេទ្យ អាហារដ្ឋាននៅសាកលវិទ្យាល័យកន្ត្រកម្ហូបអាហារ (food baskets) និងកម្មវិធីប្រើប្រាស់ប័ណ្ណអាហារ (voucher programmes) | - ចំនួននៃការពិនិត្យជាមួយនឹងចំណុចចាប់ផ្តើមនៃការបញ្ចូលមីក្រូសារជាតិដែលបានធ្វើឡើង | 0 | ១ | | NCN, DP | ២០២៩-២០៣០ |
| **គោលចំណងយុទ្ធសាស្ត្រទី៣** : បង្កើនការផលិតអាហារដែលសុវត្ថិភាព និងអាហារដែលបញ្ចូលមីក្រូសារជាតិឱ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការ រួមទាំងអំបិល ទឹកត្រី ទឹកស៊ីអ៊ីវ អង្ករ និងផលិតផលផ្សេងទៀត | | | | | | | |
| **លទ្ធផលសម្រេចបាន៣.១** : ពិនិត្យវាយតម្លៃទិដ្ឋភាពអាហារទូទៅ និងកំណត់រកផលិតផលអាហារដែលសមស្របផ្សេងទៀតសម្រាប់ការបញ្ចូលមីក្រូសារជាតិ | | - ចំនួនទិដ្ឋភាពនិងការពិនិត្យបច្ចេកទេសដែលបានធ្វើឡើង | 0 | ៣ (សរុប) | របាយការណ៍ប្រចាំឆ្នាំ | NCN, DP | |
| ១ | អនុវត្តការធ្វើផែនទីផលិតផលអាហារសក្តានុពល និងការស្ទង់មតិលើបញ្ហាកង្វះមីក្រូសារជាតិ | - ចំនួននៃលំហាត់រៀបចំផែនទីផលិតផលហារដែលបានធ្វើឡើង<br>- ចំនួននៃការស្ទង់មតិដែលបានធ្វើឡើង | 0 | ១ | | NCN, DP | ២០២៥-២០២៦ |
| ២ | ធ្វើការត្រួតពិនិត្យបច្ចេកទេស និងសមត្ថភាពផលិតកម្មគ្រប់ជ្រុងជ្រោយលើឧស្សាហកម្មម្ហូបអាហារ រួមទាំងរោងចក្រផលិតអាហារដែលបញ្ចូលមីក្រូសារជាតិ ដើម្បីកំណត់ចន្លោះខ្វះខាតបច្ចេកវិទ្យានិងស្តង់ដាប្រតិបត្តិការ ដែលកំពុងប្រើប្រាស់ចំណេះដឹងនិងការអនុវត្តរបស់បុគ្គលិក បញ្ហាប្រឈម និងតម្រូវការសម្រាប់ការគាំទ្រដើម្បីពង្រីកផលិតកម្មអាហារដែលបញ្ចូលមីក្រូសារជាតិ | - ចំនួននៃការត្រួតពិនិត្យសមត្ថភាពបច្ចេកទេស និងផលិតកម្មគ្រប់ជ្រុងជ្រោយដែលបានធ្វើឡើង | 0 | ១ | | NCN, MISTI, DP | ២០២៥-២០២៦ |
| **លទ្ធផលសម្រេចបាន៣.២** : បង្កើតបរិយាកាសអំណោយផលសម្រាប់ការផលិតអាហារដែលបញ្ចូល | | - ចំនួនកិច្ចអន្តរាគមន៍ដែលផ្តោតលើការបង្កើនបរិយាកាសអំណោយផលសម្រាប់ការ | 0 | ៣ (សរុប) | របាយការណ៍ប្រចាំឆ្នាំ | NCN, MISTI, DP | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ក្នុងការផលិតនិងគោលការណ៍ណែនាំអំពីការធានានិងគ្រប់គ្រងគុណភាព (QA&QC) ផ្ទៃក្នុង | | | | | | |
| ២ | សិក្សាពីការអនុវត្តល្អបំផុត ពង្រឹង និងពង្រីកការប្រើប្រាស់ផលិតផលដែលបញ្ចូលមីក្រូសារជាតិតាមរយៈការបង្កើតភាពជាដៃគូ និងទស្សនកិច្ចសិក្សា | - ចំនួនទស្សនកិច្ចសិក្សាឬទស្សនកិច្ចផ្លាស់ប្ដូរបទពិសោធដែលបានធ្វើឡើង | ០ | ៣ | របាយការណ៍ប្រចាំឆ្នាំ | NCN, DP | ២០២៧-២០៣០ |
| ៣ | ស្វែងរកការគាំទ្របច្ចេកវិទ្យាការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារថ្មីៗ ដើម្បីសម្របខ្លួនទៅនឹងបរិបទក្នុងស្រុក | - ចំនួនបច្ចេកវិទ្យាថ្មីដែលបានកំណត់ និងវាយតម្លៃសម្រាប់ការប្រើប្រាស់ទៅតាមបរិបទក្នុងស្រុក | ០ | ១ | របាយការណ៍ប្រចាំឆ្នាំ | NCN, DP | ២០២៧-២០៣០ |
| ៤ | រៀបចំផែនទីអ្នកផ្ដល់សេវាបច្ចេកទេស និងសម្របសម្រួលទំនាក់ទំនងរវាងអ្នកផ្ដល់សេវា និងអ្នកផលិតអាហារដែលបញ្ចូលមីក្រូសារជាតិសម្រាប់សេវាបណ្ដុះបណ្ដាល | - ចំនួនវគ្គបណ្ដុះបណ្ដាលដែលធ្វើឡើងដោយអ្នកផ្ដល់សេវាដល់អ្នកផលិតអាហារដែលបញ្ចូលមីក្រូសាជាតិ | ០ | ១០ | របាយការណ៍ប្រចាំឆ្នាំ | NCN, DP | ២០២៧-២០៣០ |
| **គោលចំណងយុទ្ធសាស្ត្រទី៤** : បង្កើតបរិយាកាសអំណោយផល និង រចនាសម្ព័ន្ធលើកទឹកចិត្តធុរកិច្ចក្នុងការវិនិយោគលើវិស័យអាហារដែលបញ្ចូលមីក្រូសារជាតិ | | | | | | | |
| **លទ្ធផលសម្រេចបាន៤.១** : រចនាសម្ព័ន្ធលើកទឹកចិត្តនៃការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ ត្រូវបានបង្កើតឡើង ដើម្បីលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជនឱ្យកាន់តែច្រើន | | - ចំនួននៃកម្មវិធីលើកទឹកចិត្តដែលបានបង្កើត និងអនុម័តជាផ្លូវការដោយស្ថាប័នរាជរដ្ឋាភិបាលពាក់ព័ន្ធ (ឧទាហរណ៍ ការលើកលែងពន្ធ ការឧបត្ថម្ភធន) | ០ | ២ (សរុប) | របាយការណ៍ប្រចាំឆ្នាំ កម្មវិធី លើកទឹកចិត្ត | NCN, MISTI, MoC, DP | |
| ១ | សិក្សាសមិទ្ធិលទ្ធភាពលើកម្មវិធីជំរុញការលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជន និងពង្រឹងកម្មវិធីបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ | - ចំនួននៃការសិក្សាសមិទ្ធិលទ្ធភាព លើកទឹកចិត្តដែលបានបង្កើតឡើង ដើម្បីគាំទ្រឱ្យមានការចូលរួមពីវិស័យឯកជននៅក្នុងកម្មវិធីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ | ០ | ១ | របាយការណ៍លទ្ធផលនៃការសិក្សា | NCN, MoC, MEF, DP | ២០២៧-២០៣០ |
| ២ | សម្របសម្រួលដល់ការទទួលបានជំនួយឥតសំណង និង/ឬកម្ចីការប្រាក់ទាបពីធនាគាររដ្ឋ និង | | ០ | ១ | របាយការណ៍ប្រចាំឆ្នាំ | NCN, MoC, MISTI, DP | ២០២៥-២០៣០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ(IFIs) (ឧទាហរណ៍ ធនាគារ ARDB ធនាគារ SME IFC ជាដើម) | | | | | | |
| ៣ | ផ្តល់ការលើកទឹកចិត្តដល់អ្នកផលិតចំពោះការអនុលោមតាមស្តង់ដា និងការលើកកម្ពស់ផលិតកម្ម និងគុណភាព នៃអាហារដែលបញ្ចូលមីក្រូសារជាតិដែលមានតម្លៃសមរម្យក្នុងគោលដៅបង្កើនការប្រកួតប្រជែងនៃផលិតផលជាតិ | - ចំនួនអ្នកផលិតដែលទទួលបានការឧបត្ថម្ភធន | 0 | ៥ | របាយការណ៍ប្រចាំឆ្នាំ | NCN, MoC, MISTI, DP | ២០២៩-២០៣០ |
| ៤ | សម្របសម្រួលភាពជាដៃគូរវាងវិស័យសាធារណៈ (សាកលវិទ្យាល័យ វិទ្យាស្ថានស្រាវជ្រាវ ។ល។) និងវិស័យឯកជនដើម្បីផ្តល់ការលើកទឹកចិត្តដល់ការស្រាវជ្រាវនិងការអភិវឌ្ឍលើ បច្ចេកវិទ្យា និងនវានុវត្តន៍ ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ និងការរួមចំណែកចេញថ្លៃចំណាយវិនិយោគជាមុនដែលចាំបាច់ | - ចំនួនភាគីចូលរួមដែលបានបង្កើតឡើង | 0 | ១ | របាយការណ៍ប្រចាំឆ្នាំ | NCN, MoC, MISTI, DP | ២០២៧-២០៣០ |
| **លទ្ធផលសម្រេចបាន៤.២** : ការផ្សារភ្ជាប់ទីផ្សារកាន់តែល្អប្រសើរសម្រាប់អាហារដែលបញ្ចូលមីក្រូសារជាតិ | | - ចំនួនគំនិតផ្តួចផ្តើម / កម្មវិធីពង្រឹងការផ្សារភ្ជាប់ទំនាក់ទំនងទីផ្សារដែលបានរៀបចំឡើង | 0 | ១០ (កម្មវិធីសិក្សាពីគ្នាចំនួន ៥ និង វគ្គបណ្តុះបណ្តាលតម្រង់ទិស ចំនួន៥) | របាយការណ៍ប្រចាំឆ្នាំ របាយការណ៍កម្មវិធី | NCN, MoC, MISTI, DP | |
| ១ | ធ្វើការស្ទង់មតិទីផ្សារដើម្បីស្វែងយល់ពីហាងលក់រាយនិងតម្រូវការសក្តានុពល (បរិមាណ រំញឹកភាព ដែនគ្របដណ្តប់ភូមិសាស្ត្រ) អាហារដែលបញ្ចូលមីក្រូសារជាតិ | - ចំនួនការស្ទង់មតិទីផ្សារដែលបានធ្វើឡើង | 0 | ១ | របាយការណ៍ស្ទង់មតិ | NCN, MoC, DP | ២០២៥-២០២៦ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២ | គាំទ្រដល់ការផ្គត់ផ្គង់អាជីវកម្មរហូតដល់ការធ្វើលទ្ធកម្មសាធារណៈនៃអាហារដែលបញ្ចូលមីក្រូសារជាតិ | - ចំនួនអ្នកផលិតដែលបានភ្ជាប់ទៅនឹងដំណើរការលទ្ធកម្មសាធារណៈនៃអាហារដែលបញ្ចូលមីក្រូសារជាតិ | 0 | ៥ | របាយការណ៍ប្រចាំឆ្នាំ | NCN, DP, MOYES, MEF | ២០២៥-២០៣០ |
| ៣ | ស្វែងរកឱកាសសម្រាប់ការនាំចេញអង្ករដែលបញ្ចូលមីក្រូសារជាតិទៅកាន់ប្រទេសក្នុងតំបន់ | | 0 | ១ | | MoC, DP | ២០២៧-២០៣០ |
| ៤ | ជួយសម្រួលដល់ការរៀនសូត្រពីគ្នាទៅវិញទៅមក និងកម្មវិធី ទំនាក់ទំនង ដែលក្រុមហ៊ុនអាចចែករំលែករឿងរ៉ាវជោគជ័យ និងបញ្ហាប្រឈមនានានៅក្នុងការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ | - ចំនួនកម្មវិធីដែលបានរៀបចំឡើង | 0 | ៥ | របាយការណ៍ប្រចាំឆ្នាំ | NCN, DP | ២០២៧-២០៣០ |
| ៥ | បង្កើតករណីសិក្សាដែលបង្ហាញអំពីករណីអាជីវកម្មសម្រាប់ការវិនិយោគលើការផលិតអាហារដែលបញ្ចូលមីក្រូសារជាតិ | - ចំនួនករណីសិក្សាដែលបានបង្កើតឡើង | 0 | ១ | របាយការណ៍ប្រចាំឆ្នាំ | NCN, DP | ២០២៧-២០៣០ |
| ៦ | រៀបចំវគ្គបណ្តុះបណ្តាលតម្រង់ទិសដល់ថ្នាក់គ្រប់គ្រងឧស្សាហកម្មម្ហូបអាហារជាន់ខ្ពស់អំពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ និងសារៈសំខាន់របស់វា | - ចំនួននៃវគ្គបណ្តុះបណ្តាលតម្រង់ទិសដែលបានធ្វើឡើង | 0 | ៥ | របាយការណ៍ប្រចាំឆ្នាំ | NCN, MoC, MISTI, DP | ២០២៥-២០៣០ |
| **គោលចំណងយុទ្ធសាស្ត្រទី៥** : ពង្រឹងបទប្បញ្ញត្តិ និង ក្របខ័ណ្ឌគតិយុត្ត លើអាហារដែលបញ្ចូលមីក្រូសារជាតិនៅកម្រិតឧស្សាហកម្មនិងទីផ្សារ ដើម្បីធានាគុណភាព សុវត្ថិភាព និងការពារសិទ្ធិអ្នកបរិភោគជាសាធារណៈ | | | | | | | |
| **លទ្ធផលសម្រេចបាន៥.១** : ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិសម្រាប់ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារត្រូវបានពង្រឹង | | - ចំនួនក្របខ័ណ្ឌបទប្បញ្ញត្តិដែលបានពិនិត្យកែសម្រួល និងអនុវត្ត | 0 | ៣ (អំបិល ទឹកត្រី ទឹកស៊ីអ៊ីវ និង អង្ករដែលបញ្ចូលមីក្រូសារជាតិ) | របាយការណ៍ប្រចាំឆ្នាំ | NCN, MISTI, MoC, DP | |
| | | - ចំនួនស្តង់ដាអាហារដែលបញ្ចូលមីក្រូសារជាតិដែលបានអនុម័ត | 0 | ២ | របាយការណ៍ប្រចាំឆ្នាំ | NCN, ISC, DP | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | ស្តង់ដាដែលបានអនុម័ត | | |
| | | - ចំនួនកម្មវិធីពង្រឹងសមត្ថភាពសម្រាប់ ស្ថាប័នរដ្ឋាភិបាលទទួលបន្ទុកត្រួតពិនិត្យដែលបានអនុវត្ត | 0 | ២ | របាយការណ៍ប្រចាំឆ្នាំ | MISTI, MoC, DP | |
| ១ | ពិនិត្យ និងវិភាគបទប្បញ្ញត្តិ ស្តង់ដា និងគោលការណ៍ណែនាំដែលមានស្រាប់ ដើម្បីកំណត់រកចំណុចខ្វះខាត និងឱកាសសម្រាប់ជាព័ត៌មានក្នុងដំណើរទិសដៅឆ្ពោះទៅមុខចំពោះមុខទំនិញដូចខាងក្រោម៖ (១) អំបិលអ៊ីយ៉ូដ (២) ទឹកត្រី ទឹកស៊ីអ៊ីវមានជាតិដែក (៣) អង្ករដែលបញ្ចូលមីក្រូសារជាតិ (៤) ផលិតផលអាហារសក្តានុពលផ្សេងទៀត | - ការពិនិត្យនិងការវិភាគលើបទប្បញ្ញត្តិ ស្តង់ដា និងគោលការណ៍ណែនាំដែលបានធ្វើឡើង | 0 | ១ | របាយការណ៍ប្រចាំឆ្នាំ | NCN, DP | ២០២៥-២០២៨ |
| ២ | កែសម្រួលក្របខ័ណ្ឌនីតិប្បញ្ញត្តិ ដោយផ្អែកលើអនុសាសន៍ក្នុងចំណុច ៣.៦.១.១ រួមទាំងការកំណត់យ៉ាងច្បាស់អំពីមុខងារ និងភារកិច្ចរបស់ស្ថាប័ននីមួយៗដែលពាក់ព័ន្ធនឹងការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ | - ក្របខ័ណ្ឌច្បាប់ដែលបានកែតម្រូវ | 0 | ១ | របាយការណ៍ប្រចាំឆ្នាំ | NCN, DP | ២០២៥-២០៣០ |
| ៣ | រៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីក្របខ័ណ្ឌបទប្បញ្ញត្តិដែលបានកែសម្រួលសម្រាប់អំបិលអ៊ីយ៉ូដ និងអង្ករដែលបញ្ចូលមីក្រូសារជាតិ ព្រមទាំងអាហារដែលបញ្ចូលមីក្រូសារជាតិផ្សេងទៀតដែលមានសក្តានុពល រួមទាំងបទប្បញ្ញត្តិស្តង់ដា និងគោលការណ៍ណែនាំត្រួតពិនិត្យ | - ចំនួនសិក្ខាសាលាផ្សព្វផ្សាយដែលបានធ្វើឡើង | 0 | ៣ | របាយការណ៍ប្រចាំឆ្នាំ | NCN, DP | ២០២៥-២០៣០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៤ | បង្កើតឬពិនិត្យឡើងវិញនូវបទប្បញ្ញត្តិសម្រាប់ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ រួមទាំងប្រភេទផលិតផលអាហារប្រភេទផ្សេងទៀត និងកម្រិតនៃមីក្រូសារជាតិ ការដាក់ស្លាកសញ្ញានិងការបញ្ជាក់អំពីអាហារូបត្ថម្ភ ការណែនាំអំពីការប្រើប្រាស់សម្រាប់អាហារដែលបញ្ចូលមីក្រូសារជាតិ និងការធ្វើទីផ្សារអាហារដែលបញ្ចូលមីក្រូសារជាតិ | - ចំនួនបទប្បញ្ញត្តិដែលបានបង្កើតឡើង | 0 | ២ | របាយការណ៍ប្រចាំឆ្នាំ | NCN, NSCFF, MISTI, DP | ២០២៥-២០៣០ |
| ៥ | បង្កើតនិងអនុម័តស្តង់ដាសម្រាប់អង្ករដែលបញ្ចូលមីក្រូសារជាតិ | - ស្តង់ដាអង្ករដែលបញ្ចូលមីក្រូសារជាតិដែលបានអនុម័ត | 0 | ១ | ស្តង់ដាដែលបានអនុម័ត | NCN, NSCFF, MISTI, WFP | ២០២៥-២០២៦ |
| ៦ | បង្កើតនិងអនុវត្តកម្មវិធីពង្រឹងសមត្ថភាព សម្រាប់ស្ថាប័នរដ្ឋាភិបាលទទួលបន្ទុកត្រួតពិនិត្យគុណភាពអាហារដែលបញ្ចូលមីក្រូសារជាតិ | - ចំនួនកម្មវិធីពង្រឹងសមត្ថភាពដែលបានបង្កើតឡើង<br>- ចំនួនវគ្គបណ្តុះបណ្តាលដែលបានធ្វើឡើង | 0<br>0 | ១<br>៥ | របាយការណ៍ប្រចាំឆ្នាំ | NCN, MISTI, MoC, DP | ២០២៥-២០៣០ |
| ៧ | ពង្រឹងការអនុវត្តបទប្បញ្ញត្តិដែលតម្រូវឱ្យផលិតផលអាហារនាំចូលត្រូវអនុលោមតាមស្តង់ដានៃការបញ្ចូលមីក្រូសារជាតិក្នុងស្រុក | - ចំនួនសិក្ខាសាលាផ្សព្វផ្សាយ ឬចំនួនការផ្សព្វផ្សាយពីអនុលោមតាមស្តង់ដានៃការបញ្ចូលមីក្រូសារជាតិក្នុងស្រុក | 0 | ១២៥ | | NCN, NSCFF, MoC, DP | ២០២៥-២០៣០ |
| **លទ្ធផលសម្រេចបាន៥.២** : ការអនុលោមតាមស្តង់ដានិងបទប្បញ្ញត្តិនៃការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារក្នុងវិស័យឧស្សាហកម្ម និង ទីផ្សារត្រូវបានពង្រឹង | | - ភាគរយនៃអ្នកផលិតអំបិលអ៊ីយ៉ូដដែលអនុលោមតាមស្តង់ដា<br>- ភាគរយនៃរោងម៉ាស៊ីនកិនស្រូវដែលបញ្ចូលមីក្រូសារជាតិដែលអនុលោមតាមស្តង់ដា | - | ១០០% សម្រាប់អំបិល<br>៥០% សម្រាប់អង្ករ | របាយការណ៍អធិការកិច្ច | NCN, MISTI, MoC, DP | |
| | | - ភាគរយនៃអ្នកផលិតទឹកត្រី ទឹកស៊ីអ៊ីវមានជាតិដែកដែលអនុលោមតាមស្តង់ដា | | | | NCN, MISTI, MoC, DP | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **លទ្ធផលសម្រេចបាន៥.៣** : សមត្ថភាពរបស់ភាគីឯករាជ្យទីបីក្នុងស្រុកដែលអាចបញ្ជាក់ផ្ទៀងផ្ទាត់គុណភាពនិងកម្រិតអនុលោមភាពត្រូវបានពង្រឹង | | -ចំនួនមន្ទីរពិសោធន៍ដែលមានសមត្ថភាពវិភាគវីតាមីន និងសារជាតិរ៉ែខនិជក្នុងអាហារដែលបញ្ចូលមីក្រូសារជាតិ | 0 | ១ | របាយការណ៍ប្រចាំឆ្នាំ | MoC, MISTI | |
| | | - ចំនួនមន្ទីរពិសោធន៍ដែលទទួលបានការទទួលស្គាល់ ISO ១៧០២៥ ក្នុងការវិភាគវីតាមីននិងសារជាតិរ៉ែខនិជក្នុងអាហារដែលបញ្ចូលមីក្រូសារជាតិ | ១ | ២ | របាយការណ៍ប្រចាំឆ្នាំ | MISTI, MoC, DP | |
| ១ | ធ្វើការវាយតម្លៃសមត្ថភាពរបស់មន្ទីរពិសោធន៍ក្នុងការវិភាគសំណាកអាហារដែលបញ្ចូលមីក្រូសារជាតិរួមទាំងវីតាមីន និងសារជាតិរ៉ែខនិជ។ ការវាយតម្លៃនេះ ត្រូវគ្របដណ្តប់លើឧបករណ៍ សម្ភារៈបរិក្ខារ ជំនាញបុគ្គលិក ភស្តុភារ និងសមត្ថភាពប្រចាំឆ្នាំ | - ការវាយតម្លៃសមត្ថភាពមន្ទីរពិសោធន៍ដែលបានធ្វើឡើង | 0 | ១ | របាយការណ៍ប្រចាំឆ្នាំ | NCN, DP | ២០២៧-២០៣០ |
| ២ | បំពាក់ឧបករណ៍ចាំបាច់ និងសម្ភារៈបរិក្ខារជូនមន្ទីរពិសោធន៍ ដើម្បីធ្វើការវិភាគបែបបរិមាណលើសំណាកអាហារដែលបញ្ចូលមីក្រូសារជាតិ | - ចំនួនមន្ទីរពិសោធន៍ដែលបានបំពាក់ឧបករណ៍ចាំបាច់សំខាន់ៗ | 0 | ១ | របាយការណ៍ប្រចាំឆ្នាំ | NCN, DP | ២០២៧-២០៣០ |
| ៣ | បង្កើតគោលការណ៍ណែនាំធ្វើតេស្តស្តង់ដាសម្រាប់អាហារដែលបញ្ចូលមីក្រូសារជាតិ | - ចំនួនឯកសារណែនាំអំពីតេស្តស្តង់ដាសម្រាប់អំបិលនិងអង្ករដែលបានបង្កើតឡើង | 0 | ២ | របាយការណ៍ប្រចាំឆ្នាំ | NCN, MISTI, MoC, DP | ២០២៧-២០៣០ |
| ៤ | ផ្តល់ការបណ្តុះបណ្តាលជំនាញ សម្រាប់បុគ្គលិកមន្ទីរពិសោធន៍លើការវិភាគអាហារដែលបញ្ចូលមីក្រូសារជាតិរួមទាំងវីតាមីន និង សារធាតុរ៉ែខនិជ | - ចំនួនបុគ្គលិកមន្ទីរពិសោធន៍ដែលទទួលបានការបណ្តុះបណ្តាលអំពីការវិភាគអាហារដែលបញ្ចូលមីក្រូសារជាតិ | 0 | ១២៥ | របាយការណ៍ប្រចាំឆ្នាំ | NCN, DP | ២០២៧-២០៣០ |
| ៥ | ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដើម្បីទទួលបានការទទួលស្គាល់មន្ទីរពិសោធន៍ និង ធានាបាននូវការអនុលោមតាមស្តង់ដាអន្តរជាតិ ISO | - ចំនួនមន្ទីរពិសោធន៍ដែលទទួលបានការទទួលស្គាល់ ISO ១៧០២៥ ក្នុងការវិភាគ | ១ | ២ | របាយការណ៍ប្រចាំឆ្នាំ | NCN, DP | ២០២៧-២០៣០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | វីតាមីននិងសារជាតិរ៉ែខនិជក្នុងអាហារដែលបញ្ចូលមីក្រូសារជាតិ | | | | | |
| **គោលបំណងយុទ្ធសាស្ត្រទី៦** : បង្កើនការយល់ដឹង និង ជំរុញតម្រូវការអ្នកប្រើប្រាស់សម្រាប់អាហារដែលបញ្ចូលមីក្រូសារជាតិ | | | | | | | |
| **លទ្ធផលសម្រេចបាន៦.១**: ការយល់ដឹងរបស់សាធារណជនអំពីអាហារដែលបញ្ចូលមីក្រូសារជាតិត្រូវបានលើកកម្ពស់ | | | | | | MoInf, MoC, MRD, DP | |
| ១ | ធ្វើការអង្កេតទៅលើ ចំណេះដឹង ឥរិយាបថ និងការអនុវត្ត (KAPs) ដើម្បីប្រមូលទិន្នន័យនិងផ្តល់ជាព័ត៌មានសម្រាប់បង្កើតយុទ្ធសាស្ត្រទីផ្សារសង្គម | - ចំនួនការស្ទង់មតិ KAPs ដែលបានធ្វើឡើង | 0 | ១ | របាយការណ៍ប្រចាំឆ្នាំ របាយការណ៍ស្ទង់មតិ KAPs | NCN, MISTI, MoC, MRD, DP | ២០២៥-២០២៦ |
| ២ | បង្កើតស្លាកសញ្ញា/ម៉ាកយីហោសម្រាប់ផលិតផលអាហារនីមួយៗដែលបញ្ចូលមីក្រូសារជាតិដែលផលិតក្នុងស្រុក ដើម្បីកសាងទំនុកចិត្តនិងការយល់ដឹងក្នុងចំណោមសាធារណជន ដែលជាអ្នកប្រើប្រាស់និងសម្រេចចិត្ត | - ចំនួនម៉ាក/រូបសញ្ញាអាហារដែលបញ្ចូលមីក្រូសារជាតិដែលបានបង្កើតឡើង | 0 | ១ | | MoC | ២០២៥-២០២៦ |
| ៣ | បង្កើតនិងអនុវត្តយុទ្ធនាការលើកកម្ពស់ការយល់ដឹង (ដូចជា និមិត្តសញ្ញា អ្នកមានឥទ្ធិពល ការរៀបចំនិងធ្វើសារនៅលើស្លាកសញ្ញា អាហារបំប៉ន និងការអះអាងអំពីសុខភាព) អំពីអត្ថប្រយោជន៍របស់អាហារដែលបញ្ចូលមីក្រូសារជាតិដើម្បីអមជាមួយកម្មវិធីចែកចាយ | - ចំនួនយុទ្ធនាការលើកកម្ពស់ការយល់ដឹងដែលបានបង្កើតឡើងនិងអនុវត្ត | 0 | ១ | របាយការណ៍ប្រចាំឆ្នាំ កម្មវិធីយុទ្ធនាការ | NCN, MISTI, MoC, MRD, DP | ២០២៧-២០៣០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **លទ្ធផលសម្រេចបាន៦.២** : យុទ្ធសាស្ត្រផ្សព្វផ្សាយទីផ្សារសង្គមត្រូវបានបង្កើតឡើងនិងអនុវត្ត | | | | | | MoInf, MISTI, MoC, MRD | |
| ១ | ធ្វើការស្រាវជ្រាវប្រមូលព័ត៌មាន រួមទាំងការអង្កេតទៅលើចំណេះដឹង ឥរិយាបថ និងការអនុវត្ត (KAPs) ឆន្ទៈរបស់អ្នកប្រើប្រាស់ក្នុងការបង់ប្រាក់ និងការសិក្សាពាក់ព័ន្ធផ្សេងទៀត | - ចំនួននការសិក្សាស្រាវជ្រាវប្រមូលព័ត៌មានដែលបានធ្វើឡើង | 0 | ១ | របាយការណ៍ប្រចាំឆ្នាំ<br>របាយការណ៍ស្ទង់មតិ KAPs | NCN, MISTI MoC, DP | ២០២៥-២០២៦ |
| ២ | បង្កើតយុទ្ធសាស្ត្រទីផ្សារសង្គមផ្អែកលើភស្តុតាងដើម្បីបង្កើនការយល់ដឹងអំពីអត្ថប្រយោជន៍នៃការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ | - យុទ្ធសាស្ត្រទីផ្សារសង្គមដែលបានបង្កើតឡើង | 0 | ១ | របាយការណ៍ប្រចាំឆ្នាំ<br>យុទ្ធសាស្ត្រទីផ្សារសង្គម | NCN, MoInf, MISTI, MoC, MRD, DP | ២០២៥-២០២៦ |
| ៣ | បង្កើតនិងអនុវត្តយុទ្ធនាការទីផ្សារសង្គមពហុបណ្តាញដោយប្រើប្រាស់វិធីសាស្ត្រផ្លាស់ប្តូរឥរិយាបថសង្គមដោយផ្អែកលើការស្ទង់មតិទីផ្សារ និងអ្នកប្រើប្រាស់សម្រាប់ផលិតផលអាហារដែលបញ្ចូលមីក្រូសារជាតិនីមួយៗ | - ចំនួនយុទ្ធនាការទីផ្សារសង្គមដែលបានបង្កើតឡើងនិងអនុវត្ត | 0 | ១ | របាយការណ៍ប្រចាំឆ្នាំ | NCN, MoInf, DP | ២០២៧-២០៣០ |
| **គោលបំណងយុទ្ធសាស្ត្រទី៧** : ការធានាការផ្តល់ហិរញ្ញប្បទានសម្រាប់កម្មវិធីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ | | | | | | | |
| **លទ្ធផលសម្រេចបាន៧.១** : ហិរញ្ញប្បទានសម្រាប់អនុវត្តការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារត្រូវបានវិភាជន៍ | | - ចំនួនយុទ្ធសាស្ត្រហិរញ្ញប្បទានដែលបានបង្កើតឡើងនិងអនុវត្ត | 0 | ១ | របាយការណ៍ប្រចាំឆ្នាំ<br>យុទ្ធសាស្ត្រហិរញ្ញប្បទាន | NCN, MISTI, DP | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១ | បង្កើតផែនការសកម្មភាពដែលមានចែងក្នុងយុទ្ធសាស្ត្រនេះ | - ផែនការចំណាយសកម្មភាពថ្លៃចំណាយដែលបានបង្កើតឡើង | 0 | ១ | របាយការណ៍ប្រចាំឆ្នាំ | NCN, DP | ២០២៥-២០២៦ |
| ២ | បង្កើតផែនការហិរញ្ញប្បទានសម្រាប់យុទ្ធសាស្ត្រ និង/ឬយុទ្ធសាស្ត្រហិរញ្ញប្បទាន ដើម្បីពង្រីកវិសាលភាពកម្មវិធីជាក់លាក់ | - ផែនការហិរញ្ញប្បទានដែលបានបង្កើតឡើង | 0 | ១ | របាយការណ៍ប្រចាំឆ្នាំ | NCN, DP | ២០២៥-២០២៦ |
| ៣ | បង្កើតវិធីសាស្ត្រតស៊ូមតិ ដើម្បីប្រមូលធនធានទៅតាមផែនការ | - យុទ្ធសាស្ត្រតស៊ូមតិដែលបានបង្កើតឡើង និងអនុវត្ត | 0 | ១ | របាយការណ៍ប្រចាំឆ្នាំ | NCN, DP | ២០២៥-២០៣០ |

អនុគណៈកម្មការជាតិបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារនៅកម្ពុជា

អជមអ

NSCFF

អាហារបញ្ចូលមីក្រូសារជាតិ

ដើម្បីសុខភាពល្អ!